# ៣០ សំនួរ និង ចម្លើយ
# ស្ដីអំពី
# ប្រវត្តិភាសា និង អក្សរសាស្ត្របាលី

ប្រែ និងរៀបរៀងដោយសាស្ត្រាចារ្យ

**សឿង ឫទ្ធី**



ព្រះពុទ្ធឃោសាចារ្យ

រក្សាសិទ្ធិ

ភ្នំពេញ.កម្ពុជា

ព.ស: ២៥៥៦ គ.ស: ២០១២

អាត្មាភាពមានចំណាប់អារម្មណ៍ ផ្នែកការសិក្សាស្រាវជ្រាវឯកសារ និងក្បួនច្បាប់សៀវភៅផ្សេងៗ តាមប្រព័ន្ធអ៊ីនធឺណិត និងគេហទំព័រនានា, ជាពិសេសគេហទំព័រ www.elibraryofcambodia.org ឃើញថា ក្នុងគេហទំព័រនេះ ដាក់សៀវភៅជំនាន់ចាស់មានខ្លឹមសារល្អៗជាច្រើន និងមានដាក់វណ្ណកម្មអ្នកជំនាន់ក្រោយផងដែរ ។

អាស្រ័យហេតុនេះ, អាត្មាភាពបានសម្រេចអនុញ្ញាតឱ្យលោក វេជ្ជបណ្ឌិត **ខៅ ឃុនសំរ៉ែ** យកសៀវភៅដែលមានចំណងជើងថា "៣០ សំនួរ និងចម្លើយ ស្តីអំពីប្រវត្តិភាសា និងអក្សរសាស្ត្របាលី" ព្រមទាំងសៀវភៅផ្សេងៗទៀត ដែលសរសេរដោយខ្ញុំករុណា អាត្មាភាព និងមិត្តធម៌ ដាក់ចូលក្នុងគេហទំព័រនេះដែរ ឱ្យបានគ្រប់ទំព័រក្នុងសៀវភៅនីមួយៗ ដើម្បីផ្សព្វផ្សាយបានទូលំទូលាយ សម្រាប់ជាប្រយោជន៍ ដល់សិក្ខាកាមកុលបុត្រខ្មែរគ្រប់ជំនាន់ សិក្សាស្រាវជ្រាវយូរអង្វែងតទៅ ៕

ទីក្រុងសាន់ហូហ្សេ, រដ្ឋកាលីហ្វ័រញ៉ា, USA
ថ្ងៃចន្ទ៦រោច ខែផល្គុន ឆ្នាំមមែ ព. ស. ២៥៥៩
ត្រូវនឹងថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៦
ហត្ថលេខា

Soeurngvuthy

ភិក្ខុ **សឿន វុទ្ធី**

# មាតិកា

ទំព័រ

អារម្ភកថា-----------------------------------------------------------ក

និវេទនកថា---------------------------------------------------------គ

១. សំនួរទី១: តើបាលី មានន័យដូចម្ដេច ?----------------------- ១

២. សំនួរទី២: តើបាលីជាភាសានិយាយ ឬជាភាសាសរសេរ ?-- ១

៣. សំនួរទី៣: តើភាសាបាលីខុសគ្នាពីភាសាឆន្ទ ឬភាសាវេទ យ៉ាងដូចម្ដេច ?------------------------------------------------ ១

៤. សំនួរទី៤: តើកន្លែងណាមួយ ជាស្រុកកំណើត នៃភាសាបាលី? ------------------------------------------------------------ ២

៥. សំនួរទី៥: តើស្ថានភាពនៃភាសាបាលី ក្នុងសម័យពុទ្ធកាល មានសភាពដូចម្ដេច ? -------------------------------------------២

៦. សំនួរទី៦: ហេតុអ្វីបានជាព្រះសម្មាសម្ពុទ្ធជ្រើសរើសយកភាសាបាលីមកសំដែងធម៌ ប្រសើរជាងយកភាសាឆន្ទ (សំស្រ្កឹត)។ ៣

៧. .សំនួរទី៧: ក្នុងសម័យពុទ្ធកាល ការបង្រៀនផ្នែកសាសនាបានចែកចាយចំណេះដឹង ដោយគ្រូបង្រៀនខាងសាសនាតែតាមរយៈភាសាពិសិដ្ឋនៃគម្ពីរ ។ ព្រះពុទ្ធអង្គក៏ជាគ្រូបង្រៀនខាងសាសនាដែរ ទ្រង់បានមិនអើពើចំពោះប្រពៃណីនេះទេ ។ ព្រះអង្គបានសំដែងជាភាសារបស់មនុស្សធម្មតា ។ ហេតុអ្វី ? --- ៤

៨. សំនួរទី៨: អ្នកប្រាជ្ញពួកព្រាហ្មណ៍ជាច្រើន បានបួសជាភិក្ខុ ។ ពួកភិក្ខុមានដើមកំណើតចេញពីត្រកូលព្រាហ្មណ៍ខ្លះ បានអារាធនាព្រះពុទ្ធ ដើម្បីអនុញ្ញាតឱ្យពួកគេ បកប្រែពុទ្ធវចនៈទៅជាភាសាឆន្ទ (ភាសាសំស្រ្កឹតរបស់គម្ពីរវេទ) ។ សូមស្រង់យកអត្ថបទជាក់ស្តែង ទាក់ទងនឹងព្រឹត្តិការណ៍នេះ។ ------------- ៤

៩. សំនួរទី៩: ចូររៀបរាប់បរិយាយ នូវអត្ថបទជាមូលដ្ឋាន នៃសម្រង់ខាងលើ ។ ------------------------------------------------ ៥

១០. សំនួរទី១០: បាលីគឺជាឃ្លាំង (ភណ្ឌាគារៈ) នៃបញ្ញារបស់ព្រះពុទ្ធ ។ ហេតុអ្វីបានជាឱ្យឈ្មោះបាលីថាដូច្នេះ? -------- ៨

១១. សំនួរទី១១: ហេតុអ្វីបានជាព្រះត្រៃបិដកបាលី គេឱ្យឈ្មោះ ថាជាគម្ពីរដ៏ពិសិដ្ឋ ? ---------------------------------៩

១២. សំនួរទី១២: តើអ្វីជាឧត្តមប្រយោជន៍ប្រសើរបំផុត របស់ព្រះត្រៃបិដក? ---------------------------------------------------- ១០

១៣. សំនួរទី១៣: តើប្រយោជន៍នៃការប្រតិបត្តិ តាមអរិយមគ្គអង្គ ៨ ដូចម្តេច ? ------------------------------------------ ១០

១៤. សំនួរទី១៤: តើភាពខុសគ្នា រវាងប្រពៃណីភាសាវិទ្យារបស់ឥណ្ឌាទាំង ២ គឺ ភាសាបាលី និងសំស្រ្កឹត មានលក្ខណៈខុសគ្នាដូចម្តេច ? ------------------------------------------ ១២

១៥. សំនួរទី១៥: តើភាសាបាលីមានប្រវត្តិដូចម្តេច ? ------ ១៤

១៦. សំនួរទី១៦: តើភាសាបាលី និងភាសាសំស្រ្កឹត មួយណាចាស់ជាងមួយណា ? -------------------------------------- ១៥

១៧. សំនួរទី១៧: តើវាក្យស័ព្ទភាសាបាលីកើតចេញពីភាសាដែលមានវ័យចំណាស់ជាងណាមួយ មានដូចឆន្ទាសៈភាសាជាដើមឬ ? ---------------------------------------------- ១៦

១៨. សំនួរទី១៨: តើបាលីបាននាំចូលពាក្យថ្មីជាមួយនឹងអត្ថន័យថ្មីទៅក្នុងវាក្យស័ព្ទ របស់វាផ្ទាល់ឬ ? ------------------------ ១៦

១៩. សំនួរទី១៩: ចូររាប់ជំហាននៃការធ្វើវិវឌ្ឍន៍ ផ្នែកភាសាបាលី ។១៧

២០. សំនួរទី២០: តើអ្វីជាមូលដ្ឋានគ្រឹះនៃភាសាបាលី? ចូររៀបរាប់ឱ្យបានច្បាស់ ហើយធ្វើការវិភាគផង ។ ------------------- ១៨

២១. សំនួរទី២១: តើភាពខុសគ្នា រវាងគម្ពីរសាសនា ដូចជាគម្ពីរវេទ គម្ពីរប៊ីប គម្ពីរកូរ៉ាន់ ។ល។ និងគម្ពីរបាលីខាងពុទ្ធសាស-នា មានលក្ខណៈដូចម្តេច ? --------------------------------២០

២២. សំនួរទី២២: តើមានកន្លែងត្រង់ណា សម្រាប់ការប្រកាន់ខ្ជាប់ទាំងងងិតងងល់ ក្នុងគម្ពីរបាលីពុទ្ធសាសនាដែរឬទេ? ប្រសិនបើមិនមានព្រោះហេតុអ្វី ឬប្រសិនបើមានតើហេតុអ្វី ? --- ២៣

២៣.សំនួរទី២៣: ហេតុអ្វីបានជាគម្ពីរបាលីឱ្យឈ្មោះថាត្រៃបិដក? ចូររៀបរាប់សារៈសំខាន់នៃពាក្យបិដក (កញ្ជើ) ។ ហេតុអ្វីបានជាគម្ពីរពុទ្ធសាសនាមានឈ្មោះថា (កញ្ជើ) ?------------- ២៣

២៤.សំនួរទី២៤: នៅពេលដែលព្រះពុទ្ធទ្រង់បានបរិនិព្វាន តើមានអ្វីកើតឡើង ?---------------------------------------------២៤

២៥. សំនួរទី២៥: ចូរសរសេរព្រឹត្តិការណ៍សង្គ្រាយនាលើកទី១ ឱ្យបានពិស្តារ ។ --------------------------------------------- ២៨

២៦. សំនួរទី២៦: ចូរសរសេររៀបរាប់ ពីព្រឹត្តិការណ៍សង្គ្រាយនាលើកទី ២ ។ --------------------------------------------- ២៩

២៧. សំនួរទី២៧:ចូរសរសេររៀបរាប់សង្គ្រាយនាលើកទី៣។ ---៣៥

២៨. សំនួរទី២៨: ចូរសរសេររៀបរាប់ ពីព្រឹត្តិការណ៍សង្គ្រាយនាលើកទី៤ ។ --------------------------------------------- ៤៤

២៩. សំនួរទី២៩: ចូររៀបរាប់ពីសង្គ្រាយនាលើកទី ៥ ឱ្យបានពិស្តារ ។ --------------------------------------------- ៤៧

៣០. សំនួរទី៣០: ចូរសរសេររៀបរាប់សង្គ្រាយនាលើកទី ៦ តើបានត្រូវប្រារព្ធធ្វើនៅកន្លែងណា ? ------------------------- ៤៨

៣១. សៀវភៅផ្សេងៗដែលខ្ញុំបានប្រែរៀបរៀង និងនិពន្ធ ------- ៥២

៣២. ប្រវត្តិរូបសង្ខេបរបស់អ្នកប្រែរៀបរៀងសៀវភៅ ----------- ៥៤

# អារម្ភកថា

សៀវភៅ "**៣០ សំនួរនិងចម្លើយស្ដីអំពីប្រវត្តិភាសានិងអក្សរសាស្រ្តបាលី**" នេះច្បាប់ដើមជាភាសាអង់គ្លេស ដែលមានចំណងជើងថា "**ប្រវត្តិភាសា និងអក្សរសាស្រ្តបាលី**" និពន្ធដោយព្រះតេជគុណអាចារ្យ**ពុទ្ធរក្ខិតៈ** ជនជាតិឥណ្ឌា។ លោកជាអ្នកនិពន្ធដ៏ល្បី, ជាស្ថាបនិកទស្សនាវដ្ដីមហាពោធិ នៅប្រទេសឥណ្ឌា និងអតីតជាសមាជិកក្រុមប្រឹក្សាត្រួតពិនិត្យគម្ពីរបាលី ក្នុងសង្គាយនាលើកទី ៦, ទីក្រុងរ៉ង្គូន, ប្រទេសភូមាឆ្នាំ១៩៥៦ ផងដែរ។ ខ្ញុំបានទទួលសៀវភៅនេះ ពីព្រះសង្ឃឥណ្ឌា នាម **ធម្មរក្ខិតៈ** ក្នុងពេលដែលលោកនិមន្តមកទស្សនកិច្ចស្រុកខ្មែរយើង កាលពីថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១២ ថ្មីៗកន្លងទៅនេះ។ ព្រះសង្ឃអង្គនេះត្រូវជាកូនសិស្សរបស់លោកគ្រូ**ពុទ្ធរក្ខិតៈ** ដែលជាអ្នកនិពន្ធសៀវភៅនេះ។ លោកជាមិត្តរួមសាកលវិទ្យាល័យជាមួយខ្ញុំនៅ "**សាកលវិទ្យាល័យពុទ្ធសាសនទូតថេរវាទអន្តរជាតិ**" នៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា ។

ខ្ញុំយល់ថាសៀវភៅនេះមានសារៈសំខាន់ សម្រាប់ជនទូទៅ, ជាពិសេសអ្នកកាន់ពុទ្ធសាសនា និងអ្នកសិក្សាភាសាបាលី ព្រោះវាផ្ដល់ទិន្នន័យច្បាស់លាស់និងទាន់សម័យ ហើយមិនសាំញ៉ាំ មិនស្មុគ

ស្មាញសម្រាប់អ្នកសិក្សា ទើបខ្ញុំសម្រេចចិត្តបកប្រែវា ទៅជាខេមរៈភាសា ដើម្បីបម្រើផលប្រយោជន៍ ដល់សង្គមខ្មែរទាំងមូល ។

ខ្ញុំបានធ្វើសៀវភៅនេះជាពីរច្បាប់ ១ ច្បាប់រៀបរៀង ជារបៀបចោទឆ្លើយ គឺសៀវភៅដែលលោកអ្នកកំពុងកាន់អាន នៅក្នុងដៃនេះស្រាប់ និង ១ ច្បាប់ទៀតប្រែរៀបរៀង ជាលក្ខណៈធម្មតា ប៉ុន្តែក្រាស់ និងមានសេចក្តីពិស្តារជាងនេះ ។

ការប្រែរៀបរៀងសៀវភៅនេះ ពិតជានៅពុំទាន់បានល្អមួយរយភាគរយទេ។ ទោះបីខ្ញុំខំព្យាយាមធ្វើ ដោយប្រុងប្រយ័ត្ន និងយកចិត្តទុកដាក់ខ្លាំងក្លាយ៉ាងណាក្តី គឺពិតជាមានសេចក្តីឆ្គាំឆ្គង ឃ្លោងឃ្លា ល្បះ និងមានកំហុស ដោយអចេតនាជាក់ជាពុំខានឡើយ ។ ដូច្នេះ ខ្ញុំសូមអធ្យាស្រ័យ ពីសំណាក់មិត្តអ្នកអាន និងអ្នកសិក្សាគ្រប់មជ្ឈដ្ឋាន និងសូមទទួលយកការរិះគន់បែបស្ថាបនា ដោយរីករាយ។

**សឿន ឧុទ្ធី**

# និវេទនកថា

ខ្ញុំព្រះករុណា អាត្មាភាព សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះញាតិញោមពុទ្ធបរិស័ទខ្មែរ នៅសហរដ្ឋអាមេរិកទាំងអស់ ដែលមានសទ្ធាជ្រះថ្លាចូលចាប់មគ្គផល បោះពុម្ពសៀវភៅនេះ ។ ជាពិសេសពុទ្ធបរិស័ទ នៅទីក្រុងសាន់ហូហ្សេ រដ្ឋកាលីហ្វ័ញ៉ា ។ តាមពិតទៅ នៅស្រុកខ្មែរយើង ថ្វីត្បិតតែកំពុងមានភាពរីកចម្រើនជឿនលឿន ស្ទើរតែគ្រប់វិស័យក៏ដោយ ក៏វិស័យពុទ្ធសាសនារបស់យើងរីកចម្រើននៅមានកម្រិតទាបនៅឡើយ ព្រោះប្រទេសយើងបានបាត់បង់គម្ពីរក្បួនខ្នាតជាច្រើន ក្នុងសម័យសង្គ្រាម ។ ម្យ៉ាងទៀតអ្នកប្រាជ្ញខ្មែរក៏បានបាត់បង់ជីវិតទៅ ដោយពុំបានផ្ទេរចំណេះដឹងដល់អ្នកជំនាន់ក្រោយដោយល្អ ទើបជាហេតុនាំឲ្យយើងខ្វះខាតធនធានមនុស្សខាងពុទ្ធចក្រ និងគម្ពីរធម៌អាថ៌ផ្សេងៗ ។ ដូច្នេះ ខ្ញុំព្រះករុណា អាត្មាភាពយល់ឃើញថា ការបោះពុម្ពសៀវភៅនេះគឺជាការរួមចំណែក ក្នុងការលើកកម្ពស់វិស័យពុទ្ធសាសនាឱ្យមានភាពជឿនលឿនទៅមុខ មួយផ្នែកតូច ។ ហើយការបោះពុម្ពនេះ បើគ្មានការឧបត្ថម្ភជ្រោមជ្រែមពីសប្បុរសជនខ្មែរ នៅសហរដ្ឋអាមេរិក ជាពិសេសឧបាសិកា **សម សាមន** ទេ សៀវភៅនេះក៏មិនអាចកើតចេញ ជារូបរាងបានដែរ ។

សូមថ្លែងអំណរគុណចំពោះព្រះតេជគុណ បណ្ឌិត **ស៊ីន ស៊ី** ព្រឹទ្ធបុរស ផ្នែកមហាវិទ្យាល័យបាលី-សំស្ក្រឹត និងភាសាបរទេស នៃ

ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ ដែលព្រះអង្គចេះទាញយកអ្នកចេះដឹងនិងមានសមត្ថភាព មកធ្វើការងារបម្រើជាតិសាសនា ។

ខ្ញុំព្រះករុណាក៏សូមថ្លែងអំណរគុណ ចំពោះព្រះតេជគុណ **រឹក សាបូ** ចៅអធិការ វត្តបទុមសុផានារាម សង្កាត់គយត្របែក ក្រុងស្វាយរៀង ដែលព្រះអង្គតែងតែឧបត្ថម្ភដល់ខ្ញុំនូវបច្ច័យបួន ក្នុងការសិក្សា និងការធ្វើដំណើរជារឿយៗ ។

សូមថ្លែងអំណរគុណ ចំពោះពុទ្ធបរិស័ទចំណុះជើងវត្តពោធិ៍ និងពុទ្ធបរិស័ទចំណុះជើងវត្តបទុមសុផានារាម ដែលយកចិត្តទុកដាក់ចំពោះខ្ញុំ និងឧបត្ថម្ភខ្ញុំឱ្យបានសិក្សារៀនសូត្រ ដែលជាការចូលរួមចំណែកអភិវឌ្ឍធនធានមនុស្សរបស់ខ្មែរ ក្នុងនាមជាកូនខ្មែរ ។

សូមប្រសិទ្ធិពរជ័យជូនសប្បុរសជន និងអ្នកមានគុណូបការៈ ចំពោះខ្ញុំ ទាំងអស់ឱ្យបានសម្រេចនូវពុទ្ធពរទាំង ៤ ប្រការគឺៈ អាយុ វណ្ណៈ សុខៈ ពលៈ និងក្នុងទីអវសានជាតិ សូមឱ្យបានសម្រេចមគ្គផល និងនិព្វាន រួចចាកផុតទុក្ខទាំងពួង ក្នុងសង្សារវដ្តគ្រប់ៗគ្នា កុំបីអាក់ខានឡើយ ។

**សឿន វុទ្ធី**

# ៣០ សំនួរ និង ចម្លើយ
## ស្តីអំពី
## ប្រវត្តិភាសា និងអក្សរសាស្ត្របាលី

**សំនួរទី១**: **តើបាលី មានន័យដូចម្តេច ?**

**ចម្លើយ:** និយាយដោយសង្ខេប បាលីមានន័យ ថាពុទ្ធ-វចនៈ ។ គេឱ្យឈ្មោះថា **បាលី** ព្រោះវារក្សាទុកពុទ្ធវចនៈ តាមច្បាប់ដើម ។

**សំនួរទី២**: **តើបាលីជាភាសានិយាយ ឬជាភាសាសរសេរ?**

**ចម្លើយ:** បាលីជាភាសានិយាយផង និងជាភាសាសរសេរផង ។ វាជាភាសានិយាយ ក្នុងសម័យពុទ្ធកាល ជាភាសារបស់ជនទូទៅ ហើយវាត្រូវនិយាយសូម្បីតែបច្ចុប្បន្ន ដោយព្រះសង្ឃថេរវាទទូទាំងពិភពលោក ។ វាក៏ជាភាសាសរសេរផងដែរ ព្រោះវារក្សាទុកនូវពុទ្ធវចនៈតាមទ្រង់ទ្រាយដើម ។

**សំនួរទី៣**: **តើភាសាបាលីខុសគ្នាពីភាសាឆន្ទ ឬភាសាគម្ពីរវេទយ៉ាងដូចម្តេច?**

**ចម្លើយ:** ភាសាឆន្ទបានត្រូវគេប្រើសម្រាប់បព្វជិតព្រាហ្ម-ណ៍ ដើម្បីធ្វើពិធីផ្សេងៗ មានការបូជាយញ្ញ ។ល។ ចំណែកឯភាសាបាលី ជាភាសារបស់ជនសាមញ្ញទូទៅ ។ ដូច្នេះហើយ វាបាន

# សំនួរ និង ចម្លើយ

ត្រូវគេប្រើដើម្បីផ្សព្វផ្សាយ និងរក្សាទុកនូវពុទ្ធវចនៈតាមច្បាប់ដើម ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ និងដើម្បីសេចក្ដីចម្រើន ដល់ជនច្រើនគ្នា ។

**សំនួរទី៤**: **តើកន្លែងណាមួយ ជាស្រុកកំណើត នៃភាសាបាលី?**

**ចម្លើយ:** ស្រុកកំណើត ឬទីកន្លែងនៃភាសាបាលី គឺដែន **មគធៈ** ដែលគ្របដណ្ដប់ នៅតំបន់ដ៏ធំ នៃប្រទេសឥណ្ឌាសម័យនោះ គឺឥណ្ឌាភាគខាងកើត ខាងជើង និងភាគកណ្ដាល ។ ភាសានៃតំបន់នេះឈ្មោះថា **មាគធី** ឈ្មោះមួយទៀតហៅថា **បាលី** ។ ព្រះពុទ្ធជាម្ចាស់ បានសម្រេចការត្រាស់ដឹង និងបានចាប់ផ្ដើមបេសកកម្មសំដែងធម៌របស់ព្រះអង្គ នៅក្នុងដែនមគធៈដោយប្រើភាសារបស់ជនសាមញ្ញ ឬជនទូទៅ គឺភាសាបាលីនេះឯង ។

**សំនួរទី៥**: **តើស្ថានភាពនៃភាសាបាលី ក្នុងសម័យពុទ្ធ-កាលមានសភាពដូចម្ដេច?**

**ចម្លើយ:** ក្នុងសម័យពុទ្ធកាល ស្ថានភាពភាសាបាលី ជាគ្រាមភាសា ដែលមានស្តង់ដារ ឬមាត្រដ្ឋាន ឬជាភាសាកំណើតរបស់ជនសាមញ្ញ នៅដែនមគធៈ, ភាសានេះបានធ្វើវិវឌ្ឍន៍ទៅជាភាសាដ៏ប្រសើរ បរិសុទ្ធត្រឹមត្រូវយ៉ាងខ្ពង់ខ្ពស់ មិនមែនជាគ្រាមភាសាសុទ្ធសាធទេ ។ សព្វថ្ងៃ ដោយសារបាលីរក្សាទុកនូវពុទ្ធ-វចនៈតាមទ្រង់ទ្រាយដើម, វាក៏ត្រូវបានគេរៀន សិក្សា និងសរសេរ

យ៉ាងទូលំទូលាយ ហើយថែមទាំងត្រូវបានគេនិយាយ ក្នុងចំណោមសហគមន៍ព្រះសង្ឃថេរវាទ និងអ្នកប្រាជ្ញជាគ្រហស្ថជាដើម ។ គេអាចនិយាយបានថា ស្ថានភាពភាសាបាលីបច្ចុប្បន្ន គឺជាភាសាបុរាណមួយ ដែលមានភាពរស់រវើក ព្រោះគេប្រើវាយ៉ាងច្រើន ទាំងក្នុងការសិក្សា និងការទំនាក់ទំនង ក្រោយពីបានត្រូវគេប្រែទៅជាភាសាទំនើបទូទាំងពិភពលោក ។

**សំនួរទី៦**: **ហេតុអ្វីបានជាព្រះសម្មាសម្ពុទ្ធជ្រើសរើសយកភាសាបាលីមកសំដែងធម៌ ប្រសើរជាងយកភាសាឆន្ទ (ភាសាសំស្ក្រឹត) ។**

**ចម្លើយ:** ព្រះពុទ្ធទ្រង់បានជ្រើសរើសយកភាសាបាលី មកសំដែងធម៌ ប្រសើរជាងភាសាឆន្ទ ព្រោះហេតុផលសំខាន់ ២ យ៉ាង គឺ៖

១.ដើម្បីនាំអោយមានការផ្លាស់ប្តូរប្រាជ្ញាស្មារតី ក្នុងចំណោមមនុស្សគ្រប់ផ្នែកទាំងអស់របស់សង្គម ។ លើសពីនេះទៅទៀត គឺមិនគិតដល់ការបែងចែកវណ្ណៈ លទ្ធិ សាសនា ភេទ ។ល។ ដើម្បីជាប្រយោជន៍ដល់ជនគ្រប់រូបដូចៗគ្នា ដោយការប្រើភាសារបស់មនុស្សធម្មតា ។

២.ដើម្បីញ៉ាំងឱ្យមានកំណែទម្រង់សង្គមមួយ ដោយការលុបបំបាត់ឱ្យអស់នូវជំនឿងប់ងល់ មិច្ឆាទិដ្ឋិ ការបែងចែកវណ្ណៈ និងភាពអយុត្តិធម៌ក្នុងសង្គម ផ្អែកលើដំបូន្មាន និងជំនឿសាសនាសកល។

## សំនួរ និង ចម្លើយ

**សំនួរទី៧**:**ក្នុងសម័យពុទ្ធកាល ការបង្រៀនផ្នែកសាសនា បានចែកចាយចំណេះដឹង ដោយគ្រូបង្រៀនខាងសាសនាតែតាម រយៈភាសាពិសិដ្ឋនៃគម្ពីរ ។ ព្រះពុទ្ធអង្គក៏ជាគ្រូបង្រៀនខាងសាសនា ដែរ ទ្រង់បានមិនអើពើទេដឹងចំពោះប្រពៃណីនេះ ។ ព្រះអង្គបាន សំដែងជាភាសារបស់មនុស្សធម្មតា ។ ហេតុអ្វី ?**

**ចម្លើយ:** ដើម្បីប្រយោជន៍ទាំងអស់គ្នា មិនសម្រាប់តែ ជ្រុងមួយ ជាលក្ខណៈពិសេសជាងនេះទៅទៀត គឺសម្រាប់មនុស្ស ចំនួនច្រើនបំផុត ដូចមានព្រះពុទ្ធតម្រាស់ផ្ទាល់ព្រះឱស្ឋ របស់ព្រះ អង្គយ៉ាងច្បាស់ថា៖ "ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីចម្រើន និង ដើម្បីសេចក្ដីសុខ ទាំងទេវតា និងមនុស្សទាំងឡាយ" ។

**សំនួរទី៨**: **អ្នកប្រាជ្ញពួកព្រាហ្មណ៍ជាច្រើន បានបួសជា ភិក្ខុ។ ពួកភិក្ខុមានដើមកំណើតចេញពីត្រកូលព្រាហ្មណ៍ខ្លះ បាន អារាធនាព្រះពុទ្ធ ដើម្បីអនុញ្ញាតឱ្យពួកគេ បកប្រែពុទ្ធវចនៈទៅជា ភាសាឆន្ទ (ភាសាសំស្រ្កឹតរបស់គម្ពីរវេទ) ។** សូមស្រង់យក អត្ថបទជាក់ស្ដែង ទាក់ទងនឹងព្រឹត្តិការណ៍នេះ ដូចខាងក្រោមគឺ៖

**ចម្លើយ: ហន្ទ មយំ ភន្តេ ពុទ្ធវចនំ ឆន្ទសោ អារោបេមាតិ** ។ បពិត្រព្រះបរមគ្រូដ៏ចម្រើន! ប្រសិនបើពួកយើង បកប្រែពុទ្ធវចនៈទៅជាភាសាឆន្ទ (ភាសាស្រ្កឹតរបស់គម្ពីរវេទ) ជាភា សាគម្ពីរនោះ តើបានឬទេ ។ ព្រះពុទ្ធទ្រង់បានត្រាស់តបវិញថា "ម្នាលភិក្ខុទាំងឡាយ តថាគតបំបួសថាពុទ្ធវចនៈគប្បីត្រូវគេរៀនជា

ភាសារបស់ខ្លួនផ្ទាល់ ពោលគឺជាភាសា**មាគធី**" ។

**សំនួរទី៩**: **ចូររៀបរាប់បរិយាយ នូវអត្ថបទជាមូលដ្ឋាននៃសម្រង់ខាងលើ ។**

**ចម្លើយ:** ភិក្ខុអតីតជាព្រាហ្មណ៍បានស្នើសុំព្រះពុទ្ធ ដើម្បីអនុញ្ញាតឱ្យពួកគេបកប្រែពុទ្ធវចនៈ ទៅជាភាសាឆន្ទ ជាភាសាប្រើសម្រាប់គម្ពីរវេទ ។

ព្រះពុទ្ធទ្រង់មិនផ្តល់ការអនុញ្ញាតទេ ។ ផ្ទុយទៅវិញ ព្រះអង្គបានផ្តល់ដំបូន្មានយ៉ាងច្បាស់ថា "ពុទ្ធវចនៈ" គប្បីត្រូវគេរៀន សិក្សា និងរក្សាទុក តែក្នុងភាសាបាលីដែលជាភាសារបស់ជនធម្មតាទូទៅ ព្រោះព្រះសម្មាសម្ពុទ្ធផ្ទាល់ក៏បានសំដែងធម៌ជាភាសាបាលីដែរ ។

ប្រសិនបើព្រះពុទ្ធបានអនុញ្ញាតឱ្យពួកភិក្ខុនោះ, រឿងរ៉ាវដូចខាងក្រោមនឹងកើតមានឡើងគឺ៖

១.មានតែមនុស្សតិចតួចនឹងបានផលប្រយោជន៍ ពោលគឺព្រាហ្មណ៍ ជាបព្វជិតហ្នឹងឯង ។ ម្យ៉ាងទៀតភាសាឆន្ទ របស់គម្ពីរវេទ មានមន្តគាថា ដែលប្រើសម្រាប់តែធ្វើក្បួនវីត៍ ធ្វើពិធីផ្សេងៗខាងសាសនាព្រាហ្មណ៍ មានការបូជាយញ្ញជាដើម ។ ពុទ្ធសាសនាច្រានចោលវីតិនិយម (ការនិយមឱ្យមានពិធីច្រើន) ថាជាការប្រតិបត្តិជំនឿបង់ល់ខ្វះហេតុផល ដែលរាំងស្ទះដល់ការរីកលូតលាស់ ផ្នែកប្រាជ្ញាស្មារតី ។

២.ព្រះធម៌ដ៏បរិសុទ្ធ របស់ព្រះសម្មាសម្ពុទ្ធ នឹងធ្វើឱ្យល្អក់កករ

ដោយការលាយឡំជាមួយគាថាមន្តគម្ពីរវេទ ហើយដាក់បន្ថែមនូវប្រការ ដែលមិនបានសម្តែងដោយព្រះសម្មាសម្ពុទ្ធ ។

៣.តាមធម្មតាការធ្វើពិធីរីត៍ និងការបូជាយញ្ញ ជាមូលដ្ឋាន, ប្រសិនបើភាសាឆន្ទរបស់គម្ពីរវេទ បានត្រូវធ្វើឱ្យលាយឡំជាមួយព្រះធម៌, ជាលទ្ធផលនឹងបង្កើតឱ្យមានជំនឿខ្វាក់ និងងប់ងល់ ដែលនាំទៅរកការស្ថាបនាពុទ្ធសាសនាខុស ក្នុងចំណោមមនុស្សទូទៅ ។

៤.វានឹងក្លាយជាឧបសគ្គដ៏ធំមួយ ដល់មហាបេសកកម្ម របស់ព្រះពុទ្ធក្នុងការរំដោះសត្វទាំងឡាយ ចេញពីសេចក្តីទុក្ខ ។ ដូចនេះទិសដៅជាមូលដ្ឋាន នៃការត្រាស់ដឹងរបស់ព្រះអង្គ នឹងនៅមិនទាន់បានសព្វគ្រប់ និងមិនទាន់បានបំពេញ ។ ប្រសិនបើព្រះពុទ្ធ មិនបានរារាំង យ៉ាងតឹងរ៉ឹងចំពោះពួកភិក្ខុដើមកំណើតជាព្រាហ្មណ៍នោះទេ, រឿងរ៉ាវទាំងឡាយដូចខាងក្រោមនឹងមិនបានកើតឡើងគឺ៖

ក. ព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធនឹងមិនបាននាំមក នូវការផ្លាស់ប្តូរខាងប្រាជ្ញាស្មារតី ទាំងកម្រិតបុគ្គល និងសមូហភាព ។ វានឹងធ្វើឱ្យខកខាន ដើម្បីលុបបំបាត់នូវជំនឿខ្វាក់ ជំនឿឆ្វេងនិយម លទ្ធិរីតិនិយម និងភាពអយុត្តិធម៌របស់សង្គម ។ល។

ខ. ព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធនឹងមិនបានតាំងនៅឥតខ្ចោះ និងបរិសុទ្ធដូចក្នុងពេលបច្ចុប្បន្នឡើយ។ ព្រះធម៌នេះក៏នឹងត្រូវបានធ្វើឱ្យល្អក់កករទាំងស្រុង ឬក៏នឹងធ្វើឱ្យបាត់បង់ពីលោកនេះដែរ ។

គ. ព្រះពុទ្ធសាសនានឹងមិនបានស្ថិតនៅ រហូតដល់បច្ចុប្បន្ន

ឡើយ ។ ជាភ័ព្វសំណាងល្អ ដោយសារតែដំបូន្មានរបស់ព្រះពុទ្ធធ្វើបានទាន់ពេលវេលា, ឥឡូវព្រះធម៌នឹងនៅតែមិនអាចប្រែប្រួលបាន អស់រយៈពេលជាង ២៥៥០ ឆ្នាំកន្លងមកហើយ និងនៅអាចបំភ្លឺសព្វសត្វ បន្ទាប់ពីជំនាន់មួយទៅជំនាន់មួយ ។

បេសកកម្មដ៏ប្រសើរ របស់ព្រះសម្មាសម្ពុទ្ធ នឹងមិនអាចបំពេញបានទេ ។ ព្រះអង្គបានមានឧបសគ្គ អស់រយៈពេល ៤ អសង្ខេយ្យ និង ១ សែនកប្ប ដើម្បីបំពេញបេសកកម្មនេះ ។

ចំណុចខាងលើបង្ហាញថា ដោយប្រកបដោយមហាករុណា និងបញ្ញាគុណ, ព្រះសម្មាសម្ពុទ្ធទ្រង់មិនអនុញ្ញាតឱ្យភិក្ខុទាំងនោះបកប្រែព្រះធម៌ព្រះអង្គ ទៅជាភាសាសំស្ក្រឹត ដែលជាភាសាឆន្ទរបស់គម្ពីរវេទឡើយ ។

ព្រះពុទ្ធទ្រង់បានធ្វើឱ្យឥតខ្ចោះនូវសេចក្ដីករុណា របស់ព្រះអង្គ តាំងពីសម័យព្រះពុទ្ធ ព្រះនាមទីបង្ករ (ព្រះពុទ្ធទី ២៤ មុនព្រះអង្គ) ដោយការបូជាការត្រាស់ដឹងរបស់ព្រះអង្គផ្ទាល់ ដើម្បីជាប្រ-យោជន៍ និងសេចក្ដីសុខដល់ទេវតា និងមនុស្សទាំងឡាយ ។ តាមរយៈបញ្ញារបស់ព្រះអង្គ, ព្រះពុទ្ធទីបង្ករជាម្ចាស់ ទ្រង់បានទតឃើញនូវការបំពេញបារមីទាំង ១០ របស់ព្រះគោតម ៣ ដងផ្លាយ ដើម្បីបានសម្រេចជាពុទ្ធភាវៈ ហើយស្រោចស្រង់មនុស្សលោក ។

ប្រសិនបើព្រះពុទ្ធ ទ្រង់មិនបានទូន្មានភិក្ខុទាំងនោះទេ, ករុណាបារមី និងបញ្ញាបារមី នឹងនៅមិនបានបំពេញឡើយ ។ ដោយ

ការខកខាន ក្នុងបេសកកម្មទាំងនេះ, ព្រះអង្គក៏គង់នឹងខកខាន ក្នុងការដើរតួយ៉ាងសំខាន់ (ជាព្រះតថាគត អ្នកកាន់នូវសច្ចៈ) ដោយពិត។

តថាគតមានន័យថាបុគ្គលដែលបានមក (តថា + អាគតោ) ដោយការបំពេញនូវបារមីទាំង ១០ ជាង ៣ ដង ដូចព្រះពុទ្ធមុនៗ ។

បុគ្គលដែលបានទៅ (តថា + គតោ) ដោយការប្រតិស្ឋាននូវព្រះពុទ្ធសាសនា ដូចព្រះពុទ្ធពីខាងដើម ។

បុគ្គលដែលបានបង្រៀន (តថា + គតោ) នូវធម៌ដ៏ប្រសើរបំផុតដែលនាំទៅរកការត្រាស់ដឹង និងបំភ្លឺនូវជីវិត របស់សព្វសត្វទាំងពួងរាប់មិនអស់ បន្ទាប់ពីជំនាន់មួយទៅមួយទៀត ។

**សំនួរទី១០: បាលីគឺជាឃ្លាំង (ភណ្ឌាគារៈ) នៃបញ្ញារបស់ព្រះពុទ្ធ ។ ហេតុអ្វីបានជាឱ្យឈ្មោះបាលីថាដូច្នេះ ?**

**ចម្លើយ:** ឃ្លាំងគឺជាកន្លែងមួយ ដែលវត្ថុទាំងឡាយត្រូវបានយកទៅដាក់ខាងក្នុង ស្តុកទុក ហើយយកចេញមកប្រើ ទៅតាមសេចក្តីត្រូវការរបស់ខ្លួន ។

បាលីក៏ត្រូវបានឱ្យឈ្មោះថា ជាឃ្លាំងនៃបញ្ញារបស់ព្រះពុទ្ធ ព្រោះវារក្សានូវព្រះត្រៃបិដក (កញ្ចើទាំង ៣) គឺ៖ ព្រះវិន័យបិដក ព្រះសូត្របិដក និងព្រះអភិធម្មបិដក បង្កើតបានជាធម្មកាយ ជាកាយគឺប្រាជ្ញាស្មារតីរបស់ព្រះពុទ្ធ ។ ព្រះត្រៃបិដកផ្ទុកនូវអ្វី ដែលព្រះពុទ្ធទ្រង់បានសំដែង ក្នុងអំឡុងពេល ៤៥ វស្សា នៃបេសកកម្ម

របស់ព្រះអង្គ ដែលប្រកបដោយសេចក្តីករុណានោះ ។ អ្វីដែលជាខ្លឹមសារ ដែលព្រះអង្គទ្រង់បានសម្តែង គឺអរិយមគ្គមានអង្គ ៨ រួមមានសីល សមាធិ បញ្ញា ដែលនាំទៅរកការរំដោះចេញ ពីសេចក្តីទុក្ខទាំងស្រុង ។ ជាមួយភាសាបាលី ដែលប្រៀបបានដូចជាឃ្លាំងពុទ្ធវចនៈទាំងឡាយ ត្រូវបានផ្ទេរឱ្យដោយជោគជ័យ ពីជំនាន់មួយទៅជំនាន់មួយ តាមចង្វាក់ជាប់មិនដាច់ ពីគ្រូទៅកាន់សិស្ស ហើយបានផ្តល់ប្រយោជន៍យ៉ាងច្រើន ដល់មនុស្សជាតិដូច្នោះដែរ។

**សំនួរទី១១**: **ហេតុអ្វីបានព្រះត្រៃបិដកបាលី គេឱ្យឈ្មោះថាជាគម្ពីរដ៏ពិសិដ្ឋ?**

**ចម្លើយ:** គេឱ្យឈ្មោះព្រះត្រៃបិដកបាលី ថាជាគម្ពីរដ៏ពិសិដ្ឋ ព្រោះវាផ្ទុកពាក្យដ៏ប្រសើរ របស់ព្រះសម្មាសម្ពុទ្ធ ដែលឈរលើសច្ចៈភាព និងបញ្ញា, មិនមែនជាការលាតត្រដាងអំណាចអាទិទេព ។ ការត្រាស់ដឹងរបស់ព្រះអង្គបង្កឱ្យព្រះអង្គ អាចរំដោះសព្វសត្វទាំងឡាយ ចេញពីសេចក្តីទុក្ខក្នុងវដ្តៈ។ គម្ពីរមិនមែនពិសិដ្ឋ តាមរបៀបគម្ពីរដទៃ ដែលគេយល់ឃើញថា ជាការលាតត្រដាង ដោយព្រះអាទិទេពនោះឡើយ ។ គម្ពីរបាលីពិសិដ្ឋ ព្រោះវាផ្ទុកនូវសច្ចៈភាពមិនប្រែប្រួល ដែលនាំបុគ្គលទៅរក ការត្រាស់ដឹងនោះឯង ។

បាលីមានន័យជាក់លាក់ថា អត្ថបទនៃគម្ពីរបាលី ដែលផ្ទុកនូវពុទ្ធវចនៈដើម ឱ្យស្ថិតក្នុងភាពបរិសុទ្ធ តាមទ្រង់ទ្រាយដើមរបស់

វា ដោយគ្មានការដាក់បន្ថែម ឬយកចេញ សូម្បីតែមួយពាក្យ ចំពោះអ្វីដែលព្រះពុទ្ធអង្គទ្រង់បានសម្តែង ដោយព្រះអង្គផ្ទាល់ឡើយ។

**សំនួរទី១២**: **តើអ្វីជាឧត្តមប្រយោជន៍ប្រសើរបំផុត របស់ព្រះត្រៃបិដក?**

**ចម្លើយ:** គេហៅព្រះត្រៃបិដកថា ជាឃ្លាំង ឬកន្លែងដាក់ទុកនូវពុទ្ធធម៌ ព្រោះវាស្តុក និងរក្សាទុកនូវពុទ្ធវចនៈទាំងស្រុង ដែលព្រះអង្គទ្រង់បានសម្តែង រយៈពេល ៤៥ វស្សា ក្នុងការចែកចាយព្រះធម៌ ដ៏ជោគជ័យរបស់ព្រះអង្គ ។

ត្រៃបិដកក៏ឱ្យឈ្មោះថា **បរិយត្តិ** ដោយទីបំផុតឈានទៅដល់ការបដិបត្តិ គឺការប្រតិបត្តិនូវធម៌ ដោយសារការរៀនជាទ្រឹស្តីសុទ្ធសាធ មិនអាចគ្រប់គ្រាន់ ដើម្បីធ្វើឱ្យជាក់ច្បាស់ (បដិវេធៈ) នូវព្រះនិព្វាន ។ ដោយវិធី ៣ យ៉ាងនេះ គឺ **បរិយត្តិ បដិបត្តិ** និង**បដិវេធៈ** បុគ្គលគប្បីធ្វើឱ្យជាក់ច្បាស់នូវអរិយមគ្គអង្គ ៨ ដែលបែងចែកជា ៣ ដំណាក់ក្នុងការអប់រំចិត្ត ពោលគឺ **សីល សមាធិ** និង**បញ្ញា** ។

**សំនួទី១៣**: **តើប្រយោជន៍នៃការប្រតិបត្តិ តាមអរិយមគ្គអង្គ ៨ ដូចម្តេច ?**

**ចម្លើយ:** ប្រយោជន៍នៃការប្រតិបត្តិ តាមអរិយមគ្គអង្គ ៨ គឺអាចមើលឃើញ និងអាចត្រួតពិនិត្យ ឱ្យដឹងខុសត្រូវបាន (**សន្ទិដ្ឋិកោ**) ទាំងក្នុងលោកនេះ និងបរលោកនាយ ។ តួយ៉ាង បុគ្គលដែលប្រតិបត្តិនូវសីល រមែងរស់យ៉ាងរីករាយទាំងក្នុងលោក

នេះ និងលោកខាងមុខ ។ ក្នុងលោកនេះ បុគ្គលនោះរមែងបានរួចចាកពីវិប្បដិសារី សេចក្តីក្តៅក្រហាយស្តាយក្រោយ និងសេចក្តីភ័យខ្លាច ។ ហើយនៅពេលដែលបុគ្គលនោះស្លាប់ទៅ នឹងបានទៅកើតក្នុងឋានមនុស្ស ឬទេវតាជាកន្លែង ដែលមានល័ក្ខខ័ណ្ឌអំណោយផលទាំងអស់ សម្រាប់ការលូតលាស់ប្រាជ្ញាស្មារតី, តទៅទៀតដូចជាកើត ក្នុងតំបន់ត្រូវគ្នា, គ្រួសារពុទ្ធសាសនិកដែលមានសទ្ធាដូចគ្នា ហើយមានមិត្តភ័ក្តិ និងគ្រូអាចារ្យ ជាអ្នកមានគុណធម៌ ។ល។ ល័ក្ខខ័ណ្ឌទាំងនេះអាចបង្កលក្ខណៈងាយស្រួល ឱ្យបុគ្គលនោះ អាចបួសជាភិក្ខុ ជាអ្នកប្រតិបត្តិអប់រំចិត្តពេញលេញ រួចឈានទៅដល់ការសម្រេចនូវការត្រាស់ដឹង (**និព្វាន**) ។

បុគ្គលដែលប្រតិបត្តិភាវនា និងចម្រើននូវសមាធិ ក៏រស់នៅយ៉ាងរីករាយ ទាំងក្នុងពេលបច្ចុប្បន្ននេះ និងបរលោកនាយ រីករាយគ្រប់ខណៈពេលនៃជីវិត តាមរយៈសេចក្តីស្ងប់ក្នុងចិត្ត ។ ហើយបន្ទាប់ពីស្លាប់ទៅ បុគ្គលនោះនឹងទៅកើតជាទេវតា ក្នុងឋានទេវតា ឬកើតជាព្រហ្ម ក្នុងឋានព្រហ្ម ដែលជាកន្លែងបុគ្គលសោយនូវសេចក្តីសុខយ៉ាងក្រៃលែង និងមានអាយុវែង ហើយធ្វើអោយមានភាពលូតលាស់ ផ្នែកស្មារតីតទៅទៀត ។

ដូចគ្នាបុគ្គលដែលចម្រើននូវបញ្ញា ក៏រមែងរស់នៅដោយរីករាយ ក្រោមកាលៈទេសៈទាំងអស់ ។ ហើយទីបំផុតបានចាក់ធ្លុះនូវបរមត្ថធម៌ មើលឃើញនូវអ្វីៗគ្រប់យ៉ាង តាមសភាវពិត ធ្វើជាក់

ច្បាស់នូវព្រះនិព្វាន ដែលជាសភាវៈមានសេចក្តីសុខស្ងប់ និង សេរីភាពខ្ពង់ខ្ពស់បំផុត ។

ដូច្នេះទីបំផុត ត្រៃបិដកគឺការប្រតិបត្តិតាមលំដាប់លំដោយ ដែលនាំទៅរកសេចក្តីសុខ ទាំងក្នុងជាតិនេះ និងជាតិខាងមុខ រហូត បុគ្គលបានសម្រេចនូវព្រះនិព្វាន ដែលជាសភាវៈសុខយ៉ាងខ្ពង់ខ្ពស់ ក្រៃលែង ។ ព្រះពុទ្ធទ្រង់បានត្រាស់ថា "**និព្វានំ បរមំ សុខំ**" ព្រះ និព្វានជាសុខដ៏ឧត្តម" ។

**សំនួរទី១៤**: **តើភាពខុសគ្នា រវាងប្រពៃណីភាសាវិទ្យា របស់ឥណ្ឌាទាំង ២ គឺ ភាសាបាលី និងសំស្រ្កឹត មានលក្ខណៈខុស គ្នាដូចម្តេច ?**

**ចម្លើយ:** ភាពខុសគ្នា រវាងប្រពៃណីភាសាវិទ្យាទាំង ២ របស់ឥណ្ឌា គឺភាសាបាលី និងឆន្ទាសៈ ដែលប្រៀបប្រដូចទៅនឹង ស្ទឹង ដែលកំពុងហូរស្របគ្នាពីរ ដែលញែកដោយជម្រៀកដី ។ ខណៈដែលបាលីជាភាសា របស់**មាគធី-ប្រាក្រិត** របស់ពួកអារ្យ៉ន សម័យកណ្តាល ជាស្ទឹង ១ ភាសាឆន្ទាសៈបង្កើតបានជាស្ទឹង ១ ទៀត, ការលាតសន្ធឹងដី ក្នុងចន្លោះស្ទឹងទាំងពីរ ប្រៀបបានទៅនឹង ប្រពៃណីវប្បធម៌ពីរធំៗ គឺសមណៈ (សំ. ស្រមណៈ) និងប្រពៃណី ព្រាហ្មណៈ ។ ប្រពៃណីទាំងពីរនេះមានប្រព័ន្ធសង្គម និងសាសនា ផ្សេងគ្នា ។ ពួកសមណៈបានជឿលើមាគ៌ាជីវិត តាមបែបសមណៈ ដោយផ្អែកលើការចេញសាងភ្នួស ចេញពីជិវិតឃរាវាស ដើម្បី

ប្រតិបត្តិតាមផ្លូវទៅកាន់និព្វាន ដើម្បីរួចចាកសេចក្ដីទុក្ខ ក្នុងសង្សារវដ្ដ ។ ផ្ទុយទៅវិញ, ពួកព្រាហ្មណៈ ឬព្រាហ្មណ៍ បានជឿទៅលើមាគ៌ាជីវិតរបស់ឃរាវាស ថាជាផ្លូវប្រតិបត្តិ ទៅឋានសួគ៌ ដែលពួកគេចាត់ទុកថា ជាកន្លែងខ្ពង់ខ្ពស់បំផុតនោះ ។

មាគ៌ាជីវិតសាសនា របស់ព្រាហ្មណ៍ជាឃរាវាស គឺផ្អែកទៅលើប្រព័ន្ធ**វណ្ណៈស្រម** ៤ យ៉ាង ដែលមានការបែងចែកវណ្ណៈ គឺពួកព្រាហ្មណ៍ស្ថិតនៅលើវណ្ណៈខ្ពស់ជាងគេ ។ ប្រព័ន្ធវណ្ណៈស្រមតម្រង់ទិសដៅក្នុងការបង្កើតឥសី ឬឫសី ដែលអាចបន្តរៀបអាពាហ៍-ពិពាហ៍ ហើយនៅតែតំណាងឱ្យភាពខ្ពង់ខ្ពស់ របស់វប្បធម៌ពួកសមណៈ គឺជាអ្នកបួស ហើយមាននិកាយខុសៗគ្នា ។ សមណៈភាគច្រើនបំផុត ជឿលើអត្តកិលមថានុយោគ ឬជាឫសីនិយមតឹងរឹងដើម្បីជាផ្លូវប្រតិបត្តិដ៏ខ្ពង់ខ្ពស់ផ្អែកការសង្គ្រោះ ឬការរដោះទុក្ខ ។ គេប្រតិបត្តិអាក្រាតកាយនិងទម្រង់នៃទណ្ឌកម្មផ្សេងទៀត ដូចគេអាចឃើញសព្វថ្ងៃ ក្នុងចំណោមពួក**សាធុស ឬជដិល** ។

ផ្ទុយទៅនឹងទម្រង់ នៃឫសីនិយមតឹងរឹងនេះ, ពុទ្ធសាសនាបានច្រានចោលនូវប្រព័ន្ធគម្ពីរវេទ របស់ព្រាហ្មណ៍ដែលជាប្រពៃណីរបស់សមណៈ ដោយប្រតិបត្តិតាមមាគ៌ាថ្មី និងខុសគ្នាទាំងស្រុងផ្អែកការត្រាស់ដឹង នូវប្រាជ្ញាស្មារតី ឬការរំដោះចេញពីសេចក្ដីទុក្ខ, មាគ៌ានោះ ឱ្យឈ្មោះថា មជ្ឈិមបដិបទា ។ ព្រះសង្ឃក្នុងពុទ្ធសាសនាជាសមណៈ រស់នៅផ្អែកលើមូលដ្ឋានគ្រឹះ នៃមាគ៌ាកណ្ដាលនេះ

ហើយចៀសវាងនូវធម៌អមពីរយ៉ាងគឺ កាមសុខល្លិកានុយោគ និង អត្តកិលមថានុយោគ ។

គ្រហស្ថពុទ្ធសាសនា ក៏បានដឹកនាំជីវិតឃរាវាស ផ្អែកលើវិធីសាស្ត្រ នៃមាគ៌ាកណ្តាលនេះដែរ ។ ហើយទោះបីមិនប្រព្រឹត្តព្រហ្មចរិយធម៌ ដូចព្រះសង្ឃក៏ដោយ ក៏ពួកគេប្រតិបត្តិតាមប្រពៃណីសមណៈ ឬតាមឥសី ។ ពុទ្ធសាសនិកជន ដែលប្រតិបត្តិតាមប្រពៃណីសមណៈ ជាកម្មសិទ្ធិខាងខ្សែភាសាវិទ្យាប្រាក្រិត, ខណៈដែលជនទាំងឡាយ ប្រតិបត្តិប្រពៃណីព្រាហ្មណ៍ ជាកម្មសិទ្ធខាងខ្សែវប្បធម៌នៃពួកព្រាហ្មណ៍ ដែលប្រើភាសាវេទ សម័យដើមបង្អស់ ។ ខ្សែវប្បធម៌ និងភាសាវិទ្យាទាំងពីរនេះ បានតាំងនៅប្រកៀកគ្នា, ពេលខ្លះ ចុះសម្រុងគ្នា ពេលខ្លះ មិនចុះសម្រុងគ្នាទេ ។

**សំនួរទី១៥**: **តើភាសាបាលីមានប្រវត្តិដូចម្តេច?**

**ចម្លើយ:** នៅពេលដែលព្រះសម្មាសម្ពុទ្ធ ទ្រង់បានប្រកាន់យកភាសាបាលី ដើម្បីពាំនាំនូវឱវាទ របស់ព្រះអង្គគឺព្រះធម៌នេះឯង, ភាសានេះបានអភិវឌ្ឍទៅជា**មាគធី-ប្រាក្រិត** ដោយល្អរួចស្រេចទៅហើយ ។ ដោយសារវាជាភាសា ដែលបានអនុវត្តក្នុងសម័យពុទ្ធកាល, យ៉ាងហោចណាស់ ក៏វាត្រូវការពេល ៥០០ ឆ្នាំ ដើម្បីធ្វើវិវឌ្ឍន៍ និងធ្វើឱ្យប្រសើរឡើងដូច្នេះដែរ ។ ដោយសារតែហេតុនេះហើយ ទើបព្រះសម្មាសម្ពុទ្ធ ទ្រង់បានជ្រើសរើសភាសានេះ ដើម្បីពាំនាំនូវឱវាទ របស់ព្រះអង្គជាជាងការជ្រើសយកភាសាដទៃ។

បន្ទាប់ពីបានជ្រើសរើសភាសានេះ ជាគ្រឿងប្រដាប់សម្រាប់ព្រះធម៌ហើយ, ព្រះសម្មាសម្ពុទ្ធទ្រង់បាននាំបញ្ចូលពាក្យថ្មីជាច្រើន ដែលមានអត្ថន័យថ្មី ទៅក្នុងភាសានេះ ។ ជាលទ្ធផលមាគធីក្លាយជាភាសាបាលី ឬពុទ្ធវចនៈ ដែលនឹងគង់នៅមិនផ្លាស់ប្តូរ និងមិនប្រែប្រួល អស់រយៈពេល ៥០០០ ឆ្នាំ ដរាបពុទ្ធសាសនាតាំងនៅមិនបាត់បង់សាបសូន្យ ។

**សំនួរទី១៦**: **តើភាសាបាលី និងភាសាសំស្រ្កឹត មួយណាចាស់ជាងមួយណា ?**

**ចម្លើយ:** ភាសាបាលីចាស់ជាងភាសាសំស្រ្កឹត ។ហេតុផលមានដូចតទៅនេះ ៖

ភាសាសំស្រ្កឹតរបស់គម្ពីរវេទ ឬឆន្ទាសៈភាសាឥតមានវេយ្យាករណ៍ ។ វាបានត្រូវគេប្រើជា **មន្រ្ត** (ជាទម្រង់មន្តគាថា) ប៉ុន្តែមាគធី មានវេយ្យាករណ៍របស់វាផ្ទាល់ ដែលគេនិយមប្រើភាគច្រើនណាស់ ក្នុងចំណោមជនទូទៅ ។

ក្រោយមកប្រហែល ៣០០ ឆ្នាំ បន្ទាប់ពីព្រះសម្មាសម្ពុទ្ធមក, មានអ្នកចេះរៀបរៀងវេយ្យាករណ៍ម្នាក់ ជាព្រាហ្មណ៍ឈ្មោះ **បាណិនី** បានសរសេរជាលើកដំបូង នូវវេយ្យាករណ៍សម្រាប់ឆន្ទាសៈភាសា ។ ហើយគាត់ហៅថាភាសានោះថា សំស្រ្កឹត (សំ+ក្រិត) ពោលគឺជាភាសាដែលត្រូវស្ថាបនាឡើងវិញ ។ ចាប់តាំងពីពេលនោះឯង វាត្រូវបានបោះពុម្ពជាភាសា ដែលមានអក្សរ

យ៉ាងល្អមួយ ។

**សំនួរទី១៧**: **តើវាក្យស័ព្ទភាសាបាលីកើតចេញពីភាសាដែលមានវ័យចំណាស់ជាងណាមួយ មានដូចឆន្ទាសៈភាសាជាដើមឬ?**

**ចម្លើយ:** ទេ! វាក្យស័ព្ទភាសាបាលីមិនបានកើតចេញពីភាសាចាស់ជាងទេ ។ ប៉ុន្តែវាក្យស័ព្ទរបស់ភាសាបាលីបានកើតចេញពីភាសា**មាគធី-ប្រាក្រិត** ហើយដោយមានការដាក់បន្ថែម នៃពាក្យរបស់ព្រះពុទ្ធផ្ទាល់, ភាសានេះក៏ក្លាយជាពុទ្ធវចនៈ ឬបាលី ។ ក្រោយមកមាគធីបន្តផ្លាស់ប្តូរខ្លួនវាផ្ទាល់ ហើយបានក្លាយទៅជា **អបភ្រង្សៈ** ជាភាសាល្បាយមួយ ដូចជា **អរឌ្ឍមាគធី** នៃសិលាចារឹករបស់ព្រះបាទអសោក ។ ក្រោយមកទៀត បានធ្វើឱ្យប្លែកពីគ្នា ទៅជាគ្រាមភាសាផ្សេងៗ ដូចជាហិណ្ឌី បឹង្គលី អាសាម ជាដើម ។

**សំនួរទី១៨**: **តើបាលីបាននាំចូលពាក្យថ្មី ជាមួយនឹងអត្ថន័យថ្មី ទៅក្នុងវាក្យស័ព្ទ របស់វាផ្ទាល់ឬ?**

**ចម្លើយ:** ពិតមែនហើយ! ភាសាបាលីបាននាំបញ្ចូលនូវពាក្យថ្មី ជាមួយអត្ថន័យថ្មីជាច្រើន។ ឧទាហរណ៍ៈ ពាក្យ "**ធម៌**" គេបានរកឃើញ ទាំងក្នុងឆន្ទាសៈភាសា និងប្រាក្រិតភាសា គឺហៅថា "**ធម្ម**" ជាភាសាបាលី ដែលមានអត្ថន័យច្បាស់ ។ ស្រដៀងគ្នានេះដែរ ពាក្យថា "**កម៌ៈ**" ទៅជា "**កម្ម**" ជាភាសាបាលី, "**និវ៌ាន**" ទៅជា "**និព្វាន**", "**សត្យ**" ទៅជា "**សច្ច**" បានផ្តល់អត្ថន័យយ៉ាងច្បាស់ ក្នុង

ភាសាបាលី ។

**សំនួរទី១៩**: **ចូររាប់ជំហាននៃការធ្វើវិវឌ្ឍន៍ ផ្នែកភាសាបាលី ។**

**ចម្លើយ:** ភាសាបាលីបានធ្វើវិវឌ្ឍន៍ ៤ ដំណាក់កាលគឺ៖

១.ភាសាគម្ពីរផ្ទុកនូវ **សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្ម** និង**វេទល្ល** ។

២.ភាសាសម្រាយ របស់គម្ពីរសម័យក្រោយ ។ ឧ. **មិលិន្ទ-បញ្ហា កថាវត្ថុ** ។ល។

៣.ភាសាផ្នែកវណ្ណកម្ម នៃការពន្យល់អធិប្បាយ (អដ្ឋកថា) ។

៤.ភាសាផ្នែកវណ្ណកម្ម នៃការពន្យល់បន្ទាប់បន្សំ (ដីកា) ។

ក្នុងដំណាក់កាលទាំងនេះ ដំណាក់កាលនីមួយៗមានដំណាក់កាលតូចៗទៀត ។ ជាតួយ៉ាង មានវណ្ណកម្ម ជាភាសាគម្ពីរបុរាណ សម្រាប់សម្គាល់យ៉ាងច្បាស់ ដូចជានៅក្នុងសុត្តនិបាត ជាភាសា ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា ទៅនឹងឆន្ទាសៈភាសា ។

**សំនួរទី២០**: **តើអ្វីជាមូលដ្ឋានគ្រឹះនៃភាសាបាលី? ចូររៀបរាប់ឱ្យបានច្បាស់ ហើយធ្វើការវិភាគផង ។**

**ចម្លើយ:** មូលដ្ឋានគ្រឹះនៃភាសាបាលីគឺពុទ្ធវចនៈ ដែលជាពាក្យហូរចេញពីការត្រាស់ដឹង របស់ព្រះសម្មាសម្ពុទ្ធផ្ទាល់ ។ វាត្រូវបានវិភាគ ទៅជាទម្រង់ ៩ យ៉ាងគឺ៖

## សំនួរ និង ចម្លើយ

**សុត្តៈ** ផ្ទុកនូវព្រះសូត្រទាំងឡាយ ដែលព្រះសម្មាសម្ពុទ្ធទ្រង់បានសម្តែងរាល់ថ្ងៃ អស់រយៈពេល ៤៥ វស្សា នៃបេសកកម្មរបស់ព្រះអង្គ ដ៏ប្រកបដោយមហាករុណាទិគុណ ។ ព្រះសូត្រទាំងនេះ ឃើញមាននៅក្នុងវណ្ណកម្មទាំងឡាយ ផ្នែកសុត្តន្តបិដកគឺៈ

**១. ទីឃនិកាយៈ** ដែលផ្ទុកនូវព្រះសូត្រវែង របស់ព្រះសម្មាសម្ពុទ្ធ ។ ពេលខ្លះព្រះពុទ្ធទ្រង់បានសម្តែងច្រើនម៉ោង គេនិយាយថា មួយយប់ពេញក៏សឹងមាន ។ បែបនេះហើយ ព្រះសូត្រទាំងនេះ ត្រូវបានរក្សាទុកក្នុងទម្រង់**ទីឃៈ** ព្រះសូត្រមានទ្រង់ទ្រាយវែង គឺមាននៅក្នុងគម្ពីរទីឃនិកាយ ។

**២. មជ្ឈិមនិកាយៈ** ដែលផ្ទុកនូវព្រះសូត្រទាំងឡាយ ដែលវែងខ្នាតកណ្តាល របស់ព្រះសម្មាសម្ពុទ្ធ លើរឿងរ៉ាវខុសៗគ្នា ព្រះសូត្រខ្លះមានសារៈសំខាន់យ៉ាងខ្លាំង ។ វាបានផ្តល់ជាព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធថ្នាក់កណ្តាល ។

**៣. សំយុត្តនិកាយៈ** ផ្ទុកនូវព្រះសូត្រទាំងឡាយលើរឿងរ៉ាវទាក់ទង់គ្នាទៅវិញទៅមក ។ ព្រះសូត្រទាំងនេះខ្លី ហើយស្មើដៃគ្នាដែលគ្របដណ្តប់លើរឿងរ៉ាវ ដែលឱ្យឈ្មោះនោះ ។

**៤. អង្គុត្តរនិកាយៈ** ផ្ទុកនូវព្រះសូត្រទាំងឡាយ ដែលរៀបចំតាមលំដាប់លេខរៀង ជាតួយ៉ាង ព្រះសូត្រនានា ដែលទាក់ទងនឹងរឿងរ៉ាវ ១ ឬរឿងរ៉ាវ ២ ឬក៏ច្រើនជាងនេះទៀត។

**៥. ខុទ្ទកនិកាយៈ** ពួកធម៌ទាំងឡាយ ជាទម្រង់នៃការ

ពន្យល់ដោយសង្ខេប ។ និកាយនេះផ្ទុកនូវវណ្ណកម្មផ្សេងគ្នាចំនួន ៨ ដោយវណ្ណកម្មទាំងអស់ សុទ្ធតែជាអក្សរសាស្ត្រឆ្នើម និងមានសារៈសំខាន់ដល់ការអប់រំប្រាជ្ញាស្មារតី ។ ជាតួយ៉ាង គម្ពីរធម្មបទផ្ទុកនូវគាថាចំនួន ៤២៣ គាថា ដែលជាពាក្យភាសាបុរាណ ជាភាសាមិនប្រែប្រួល និយាយអំពីបញ្ញា ទាំងផ្នែកអប់រំ និងប្រតិបត្តិ ។

ប្រព័ន្ធកម្មនៃព្រះសូត្រ របស់ព្រះសម្ពុទ្ធដ៏ត្រឹមត្រូវនេះ បានផ្ដើមមានឡើង ក្នុងអំឡុងសម័យព្រះពុទ្ធ ទ្រង់នៅមានព្រះជន្ម, បន្ទាប់មក អស់ពីព្រះពុទ្ធទៅ ទីបំផុតត្រូវបានរៀបចំជាសង្គាយនាលើកទី ១ ជាលទ្ធផល នាំឱ្យមាននិកាយទាំង ៥ ឡើង ដែលបង្កើតបានជាកញ្ចើ នៃព្រះសូត្រ គឺព្រះសុត្តន្តបិដកនេះឯង ។ ពាក្យប្រៀបធៀបថា "កញ្ចើ" តាមពិតទៅគឺមានន័យស័ក្តិសមក្នុងបរិបទនេះណាស់។

**គេយ្យៈ** វាផ្ទុកនូវធាតុផ្សំមួយ ទាំងផ្នែកសេចក្ដីជាសម្រាយ និងកំណាព្យ ហើយត្រូវបានគេឃើញមាននៅក្នុង កញ្ចើទាំង ៣ នេះទាំងអស់ ។

**វេយ្យាករណៈ** វាផ្ទុកនូវវណ្ណកម្មទាំងឡាយ ខាងវិភាគដោយសំអាងទៅលើភាសា ឬនិរុត្តិវិទ្យា ពាក្យបង្រៀន លទ្ធិ ឬទស្សនវិជ្ជា។

**គាថាៈ** វាផ្ទុកនូវគាថា ជាបទផ្សេងៗគ្នា ។ ស្រទាប់ភាសាបាលីចាស់បំផុតមួយចំនួន ត្រូវបានគេរកឃើញក្នុងទម្រង់គាថា

បែបនេះ ។

**ឧទាន ឥតិវុត្តកៈ ជាតក** វណ្ណកម្មទាំង ៣ នេះជាទម្រង់ខុសគ្នា នៃពុទ្ធវចនៈ ។ ជាតួយ៉ាង, **ឧទាន**ផ្ទុកនូវវាចាបន្លឺឡើងរបស់ព្រះពុទ្ធ ដោយលើកទឹកចិត្ត ។ **ឥតិវុត្តកៈ** "គេបាននិយាយដូច្នេះថា" នេះជាប្រភេទធម៌ពិសេសប្លែកមួយទៀត ។ **ជាតក**ជារឿងដំណាល ពីជីវិតទាំងឡាយ ក្នុងអតីតកាលរបស់ព្រះពុទ្ធ ។ រឿងរ៉ាវទាំងនោះលាតត្រដាង ពីរបៀបដែលព្រះពុទ្ធ បានធ្វើវិវឌ្ឍន៍ចេញពីព្រះពោធិសត្វ ដោយការបំពេញបារមីទាំង ១០ អប់រំបន្ទំគុណធម៌ពីជីវិតមួយទៅជីវិតមួយ អស់រយៈពេលជាច្រើនអសង្ខេយ្យ ។

**អព្ភូតធម្មៈ** ផ្ទុកនូវធម៌ និយាយពីអភិញ្ញារបស់ព្រះពុទ្ធដូចដែលបានសម្តែងនៅក្នុងឱកាស និងទីកន្លែងជាច្រើន ដើម្បីនាំមកនូវសច្ចៈធម៌ ក្នុងចំណោមអ្នកស្តាប់ ឬក្នុងបុគ្គលដែលត្រូវសម្តែងនោះ ។

**សំនួរទី២១**: **តើភាពខុសគ្នា រវាងគម្ពីរសាសនា ដូចជាគម្ពីរវេទ គម្ពីរប៊ីប គម្ពីរកូរ៉ាន់ ។ល។ និងគម្ពីរបាលីខាងពុទ្ធសាសនាមានលក្ខណៈដូចម្តេច?**

**ចម្លើយ:** ខាងក្រោមនេះជាភាពខុសគ្នា រវាងគម្ពីរសាសនាដទៃ និងគម្ពីរបាលី (ត្រៃបិដក) ។ គម្ពីរបាលីគឺជាពាក្យរបស់ព្រះពុទ្ធ ដែលទោះជាមនុស្សក៏ដោយ ក៏ព្រះអង្គជាមនុស្សខ្ពង់ខ្ពស់ គឺមនុស្សកំពូលមនុស្ស និងជាសាស្តាចារ្យ នៃទេវតា និងមនុស្សទាំង

ឡាយ ។ ចំណែកឯគម្ពីរសាសនាដទៃ គឺជាការលាតត្រដាងរបស់ព្រះ ឬអាទិទេព, ព្រះធម៌ផ្អែកគម្ពីរបាលី មិនមែនជាការលាតត្រដាងដោយអាទិទេពទេ, ប៉ុន្តែជាផ្លូវមធ្យោបាយនាំទៅរកព្រះនិព្វានបង្កើតបានជារបកកំហើញ របស់បុគ្គលដែលធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វានដោយខ្លួនឯង ។ ព្រះធម៌ផ្ទុកនូវគោលការណ៍ទាំងឡាយ ចំពោះសច្ចភាព ដូចដែលធ្វើឱ្យជាក់ច្បាស់, ពិសោធ និងបង្ហាញភ័ស្តុតាងដោយព្រះពុទ្ធផ្ទាល់ ។

គម្ពីរបាលីគឺផ្អែកទៅលើធម្មៈ ចំណែកគម្ពីរសាសនាដទៃគឺផ្អែកលើតួអង្គហួសវិស័យធម្មតា ឬតួអង្គអាទិទេព ដែលទាមទារឱ្យមានជំនឿខ្វាក់ ហើយដែលគេមិនអាចចោទសួរបានទេ ។ ការលាតត្រដាងរបស់អាទិទេពគឺជា**សិទ្ធាន្ត** ជាការត្រូវគោរពសេចក្តីពិតប្រកែកមិនបាន ដែលគេមិនអាចបង្ហាញភ័ស្តុតាង ថាតើវាជារឿងខុស ឬត្រូវ ពិត ឬមិនពិតឡើយ ។

ផ្ទុយទៅវិញ, ព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ ដែលគេឃើញមានក្នុងគម្ពីរ គឺត្រូវធ្វើឱ្យជាក់ច្បាស់ផ្ទាល់ ដោយសាវ័កនីមួយៗ ហើយដើម្បីធ្វើដូច្នោះ, បុគ្គលគប្បីស៊ើបអង្កេត និងចោទសួរបាន ដើម្បីធ្វើឱ្យមានសុពលភាព ដល់តថភាពក្នុងជីវិត របស់ខ្លួនផ្ទាល់។

ពុំមានបុគ្គល ដទៃណាមួយ អាចដើរតួជាអ្នកតំណាង ដើម្បីធ្វើពិសោធន៍ នូវសច្ចធម៌នេះបានឡើយ ។ ហេតុដូច្នេះ ទើបធម៌របស់ព្រះសម្មាសម្ពុទ្ធ ត្រូវបានពន្យល់ តាមពាក្យដូចខាងក្រោម៖

## សំនួរ និង ចម្លើយ

១.ព្រះធម៌ទាំងឡាយ របស់ព្រះពុទ្ធជាម្ចាស់ ដែលបានសម្តែងហើយ ដោយល្អ អាចធ្វើពិសោធន៍បាន ដោយសាវ័កទាំងអស់ (ស្វាក្ខាតោ ភគវតា ធម្មោ) ។

២.ដោយធម៌នោះ ត្រូវបានសម្តែងហើយ ដោយល្អ គេអាចធ្វើពិសោធន៍ធម៌នោះបាន នៅទីនេះ និងនៅវេលានេះ ។ (សន្ទិ-ដ្ឋិកោ) ។

៣.ដោយភាពច្បាស់លាស់នៃព្រះធម៌ ដែលគេអាចពិនិត្យដឹងខុសត្រូវបាន និងអាចមើលឃើញនៅទីនេះ និងឥឡូវនេះ, ធម៌នេះឯងឱ្យផលភ្លាមៗ មិនរង់ចាំកាលឡើយ ។

៤.ដោយសារហេតុផលទាំងអស់នេះហើយ, ធម៌នេះអញ្ជើញបុគ្គលឱ្យធ្វើជាក់ច្បាស់ផ្ទាល់ខ្លួន ។ ដូច្នេះហើយ បានជាមានពាក្យថា "ចូរមកហើយមើល" ដោយខ្លួនឯង (ឯហិ បស្សិកោ) ។

៥.ដោយហេតុផលទាំងអស់នេះ គេអាចមើលឃើញ អាចសាកល្បង និងបង្ហាញភ័ស្តុតាងបាន, ធម៌នោះឯងនឹងនាំបុគ្គលឱ្យឆ្ពោះទៅរកការត្រាស់ដឹង ដោយជាក់ច្បាស់ និងមិនមានកំហុស (ឱបនយិកោ) ។

៦.ហើយដោយសារហេតុផល ដូចមានខាងលើទាំងអស់នេះហើយ គេអាចធ្វើពិសោធន៍ធម៌នោះ ដោយខ្លួនគេផ្ទាល់ ពោលគឺដើម្បីធ្វើឱ្យជាក់ច្បាស់ដោយខ្លួនឯង មិនមែនដោយអ្នកតំណាងណាមួយ មិនថាជាគ្រូ ឬជាព្រះអាទិទេពឡើយ (បច្ចត្តំ វេទិតព្វោ

វិញ្ញូហីតិ) ។

**សំនួរទី២២**.តើមានកន្លែងត្រង់ណា សម្រាប់ការប្រកាន់ខ្ជាប់ទាំងងងឹតងងល់ ក្នុងគម្ពីរបាលីពុទ្ធសាសនាដែរឬទេ? ប្រសិនបើមិនមាន ព្រោះហេតុអ្វី ឬប្រសិនបើមាន តើហេតុអ្វី ?

**ចម្លើយ:**ដូចបានរៀបរាប់មកខាងលើ ក្នុងចម្លើយនៃសំនួរទី ២១ នោះស្រាប់ គឺថា ពិតជាពុំមានកន្លែងណាមួយសម្រាប់ជាប់ស្អិត ការប្រកាន់មាំ ឬភាពជាប់ទាក់ទង នឹងជំនឿខ្វាក់ណាមួយដែលជាជំនឿមិនអាចគេសួរបាន និងមិនអាចត្រួតពិនិត្យបានមានជាប់នៅ ក្នុងពុទ្ធសាសនាថេរវាទ ផ្អែកលើគម្ពីរបាលីនេះឡើយ ។

**សំនួរទី២៣**: **ហេតុអ្វីបានជាគម្ពីរបាលី ឱ្យឈ្មោះថាត្រៃបិដក ? ចូររៀបរាប់សារៈសំខាន់នៃពាក្យបិដក (កញ្ជើ) ។ ហេតុអ្វីបានជាគម្ពីរពុទ្ធសាសនាមានឈ្មោះថា (កញ្ជើ) ?**

**ចម្លើយ:** គម្ពីរបាលីឱ្យឈ្មោះថាត្រៃបិដក កញ្ជើបីព្រោះវារក្សា និងហុចឱ្យដល់អ្នកជំនាន់ក្រោយ នូវរាល់ពាក្យនៃព្រះធម៌ប្រភពដើម របស់ព្រះសម្មាសម្ពុទ្ធ ដែលព្រះអង្គទ្រង់បានសម្តែងក្នុងអំឡុងពេល ៤៥ វស្សា នៃការផ្សព្វផ្សាយព្រះធម៌នោះ។ កញ្ជើទាំងនេះផ្ទុកនូវវិន័យ សុត្តន្ត និងអភិធម្មបិដក ។ ប្រៀបបានដូចកញ្ជើត្រូវបានគេប្រើដូច្នេះដែរគឺ៖

ក. ដើម្បីរក្សាទុកអ្វីមួយ ។

ខ. ដើម្បីប្រើសម្រាប់ការងារប្រចាំថ្ងៃ ។

គ. ដើម្បីយួរអ្វីមួយពីបុគ្គល ឬកន្លែងមួយ ទៅកាន់បុគ្គល ឬកន្លែងមួយផ្សេងទៀត អ៊ីចឹងហើយ គម្ពីរបាលីឱ្យឈ្មោះថាត្រៃបិដក (កញ្ជើបី) ពីព្រោះ៖

ក. វារក្សានូវព្រះពុទ្ធវចនៈ ដែលព្រះពុទ្ធទ្រង់បានសម្តែងប្រហែលជាង ២៦០០ ឆ្នាំមកហើយ ឱ្យស្ថិតនៅតាមច្បាប់ដើម ។

ខ. គម្ពីរនេះណែនាំសាវ័កទាំងឡាយ របស់ព្រះពុទ្ធ ក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ ដើម្បីធ្វើឱ្យមានភាពលូតលាស់ ផ្នែកប្រាជ្ញាស្មារតីបានត្រឹមត្រូវ និងដើម្បីដឹកនាំជីវិតដ៏រីករាយ ទាំងក្នុងលោកនេះ និងលោកខាងមុខ រហូតដល់ព្រះនិព្វានត្រូវបានសម្រេច ។

គ. វាពាំនាំនូវពុទ្ធោវាទ ពីជំនាន់មួយទៅជំនាន់មួយ តាមរយៈចង្វាក់ប្រពៃណី ពីគ្រូទៅកាន់សិស្ស ។

**សំនួរទី២៨**: **នៅពេលដែលព្រះពុទ្ធ ទ្រង់បានបរិនិព្វាន តើមានអ្វីកើតឡើង**៖

ក. តើសុភទ្ទបាននិយាយដូចម្តេច ?

ខ. ហេតុអ្វីបានជាលោកនិយាយដូច្នេះ ?

គ. តើព្រះអរហន្ត នាម មហាកស្សបត្ថេរបានចាត់វិធានការដោះស្រាយស្ថានភាពនោះដូចម្តេច ?

**ចម្លើយ:** នៅពេលដែលព្រះសម្មាសម្ពុទ្ធទ្រង់បានចូលបរិ-និព្វាន សុភទ្ទភិក្ខុបាននិយាយទៅកាន់សង្ឃ ដែលបាននិងកំពុងទួញយំសោកដូច្នេះថា "ម្នាលភិក្ខុទាំងឡាយ កុំទួញសោកធ្វើអ្វី, កុំ

យំធ្វើអ្វី ។ ឥឡូវមហាសមណៈនោះ បានបរិនិព្វានទៅហើយ, យើងនឹងរស់បានសុខស្ងប់ ។ នៅពេលដែលលោកនៅមានព្រះជន្ម, លោកធ្លាប់និយាយថា "កុំធ្វើនេះ, កុំធ្វើនោះ" ។ ឥឡូវយើងរួចចាកច្បាប់វិន័យបែបនេះហើយ ដូច្នេះ យើងអាចធ្វើនូវអ្វី ដែលយើងចូលចិត្ត ។

សុភទ្ទបាននិយាយដូច្នេះ ព្រោះលោកជាភិក្ខុក្លែងក្លាយមួយអង្គ ។ តទៅនេះជារឿងសុភទ្ទ ដែលបានចូលបួសក្នុងសង្ឃ ។ សុភទ្ទ ពីមុនជាជាងកាត់សក់ម្នាក់ រស់នៅក្នុងភូមិមួយ ឈ្មោះ **អាលវី** ។ គាត់មានប្រពន្ធ និងកូនប្រុស ២ នាក់ ។

ថ្ងៃមួយ ព្រះសម្មាសម្ពុទ្ធ មួយអន្លើដោយសាវ័កទាំងឡាយបាននិមន្តទៅកាន់ភូមិអាលវីនោះ ។ ពេលនោះសុភទ្ទបានកត់សម្គាល់ឃើញថា ជនជាច្រើនបានដើរតាមព្រះពុទ្ធ ដោយប្រតិបត្តិតាមព្រះអង្គយ៉ាងស្មោះ ព្រមទាំងមានការគោរពថ្វាយទាន យ៉ាងសន្ធឹកសន្ធាប់ ។

ឃើញដូច្នេះ, សុភទ្ទបានធ្វើគំរោងការមួយ ដើម្បីទទួលបានលុយកាក់ និងកិត្តិយសដូចអ្នកដទៃ ។ ហេតុដូច្នេះហើយ គាត់ឱ្យកូនប្រុសទាំងពីររបស់គាត់បួសជាសង្ឃ ហើយប្រមូលលាភសក្ការៈពីប្រជាជន ក្នុងនាមព្រះសម្មាសម្ពុទ្ធ និងធម៌វិន័យរបស់ព្រះអង្គ ។ ជនទាំងឡាយបានប្រគេននូវភិក្ខុសង្ឃនោះ នូវអ្វីៗដែលគេអាចមាន ប្រកបដោយការគោរពរាប់អាន និងទុកចិត្តដ៏អស្ចារ្យ។

# សំនួរ និង ចម្លើយ

បន្ទាប់ពីអង្គាសបាននូវទេយ្យទាន, គាត់បាននិមន្តព្រះសម្មា-សម្ពុទ្ធ ព្រមទាំងសាវ័កទាំងឡាយមកកាន់ផ្ទះរបស់គាត់ ដែលជាកន្លែងជនជាច្រើន ក៏ត្រូវបានអញ្ជើញមកដែរ, ប៉ុន្តែព្រះសម្មាសម្ពុទ្ធ និងសាវ័កទាំងឡាយ មិនបានទទួលយកនូវការប្រគេនរបស់នោះទេ ព្រោះវត្ថុនោះបានមក ដោយមធ្យោបាយមិនត្រឹមត្រូវ និងដោយចេតនាមច្ឆរិយៈ សម្រាប់កេរ្តិ៍ឈ្មោះ និងកិត្តិយសប៉ុណ្ណោះ ។

នៅពេលគាត់សួរព្រះពុទ្ធថា ហេតុអ្វីបានជាមិនទទួលយកទានរបស់គាត់, ព្រះសម្មាសម្ពុទ្ធទ្រង់បានប្រាប់គាត់ថា វត្ថុដែលគាត់បម្រុងនឹងឱ្យនោះ ជារបស់បានមក ដោយមធ្យោបាយខុស ហើយប្រព្រឹត្តកន្លងនូវសិក្ខាបទ**សម្មាអាជីវៈ** ។

តាំងតែពីពេលនោះមក, ជនទាំងឡាយសូម្បីតែសមាជិកគ្រួសារគាត់ បានចាប់ផ្ដើមនិយាយឡកឡឺយដាក់គាត់ដែរ ។ ដូច្នេះ ដោយត្រូវបានស្អប់ដោយបុគ្គលគ្រប់រូប, ដោយសារហេតុនេះ គាត់បានចងគំនុំជាមួយព្រះសម្មាសម្ពុទ្ធ ។ ខណៈពេលដែលគាត់កាន់តែចាស់ទៅ គាត់បាត់បង់នូវលទ្ធភាពដើម្បីធ្វើកិច្ចការជំនួញរបស់គាត់ ។ ហើយជនទាំងឡាយបានឈប់មករកគាត់ ដោយខ្លាចក្រែងថា គាត់អាចបង្កឱ្យមានរបួសស្នាម ក្នុងខណៈពេលដែលគាត់កំពុងកោរជាដើម ។ ដូច្នេះ ដើម្បីលុបបំបាត់ នូវបញ្ហាទាំងអស់នេះ គាត់បានបួសជាព្រះសង្ឃ ដើម្បីរស់នៅដោយសុខស្រួល អស់មួយជីវិត ។

ទោះជាយ៉ាងណាក្តី ក្នុងពេលនៅជាសង្ឃ គាត់មិនបាន គោរពតាមច្បាប់វិន័យ ហើយមិនគោរពនូវព្រះថេរៈចាស់វស្សាទេ ដោយសូម្បីតែព្រះសម្មាសម្ពុទ្ធ ក៏គាត់មិនគោរពដែរ ។ នេះជាហេតុផលដែលគាត់ បាននិយាយថា "កុំយំ, កុំទួញសោកជាដើម" ។

ការពោលរបស់សុភទ្ទ បានធ្វើឱ្យឮដល់ព្រះ**មហាកស្សបត្ថេរ** ដែលបានគិតថា ឥរិយាបថនេះនឹងធ្វើឱ្យមានការគំរាមគំហែង ដល់ពុទ្ធសាសនា ។ ដូច្នេះលោកបានកោះហៅព្រះអរហន្តចំនួន ៥០០ អង្គប្រជុំជាបន្ទាន់ ។ សង្ឃដ៏បរិសុទ្ធនេះ បានសម្រេចចិត្ត ធ្វើសង្គាយនាជាលើកទី ១ នៅគុហា**សត្តបន្នី** ក្នុងក្រុងរាជគ្រឹះ ។ ព្រះបាទអជាតសត្តុបានឧបត្ថម្ភសង្គាយនានេះ ហើយព្រះមហាកស្សប-ត្ថេរបានធ្វើជាអធិបតី ។ សង្គាយនានេះ បានសូត្រព្រះត្រៃបិដកទាំងស្រុងអស់រយៈពេល ៧ ខែ ។ អ្នកសូត្រគឺ ព្រះ**ឧបាលី**សូត្រវិន័យបិដក ហើយព្រះ**អានន្ទ**សូត្រព្រះសូត្រ និងព្រះអភិធម្មបិដក។ ដូច្នេះព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ បានបន្តរក្សាទុក រហូតដល់បច្ចុប្បន្ន របស់សង្ឃថេរវាទ ។

**សំនួរទី២៥**: **ចូរសរសេរព្រឹត្តិការណ៍សង្គាយនាលើកទី ១ ឱ្យបានពិស្តារ ។**

**ចម្លើយ:** នៅពេលដែលព្រះមហាកស្សបត្ថេរ ជាព្រះអរហន្ត បានឮការពោល ប្រកបដោយសេចក្តីមិនគោរព របស់ភិក្ខុចាស់ឈ្មោះសុភទ្ទ លោកបានដឹងពីការគំរាមកំហែងដ៏ធ្ងន់ធ្ងរដល់

ព្រះពុទ្ធសាសនា ។ ដូច្នោះ លោកបានកោះប្រជុំព្រះអរហន្ត ដើម្បីសូត្រព្រះត្រៃបិដក ដើម្បីរក្សាពុទ្ធវចនៈទុក ដោយបរិសុទ្ធតាមទ្រង់ទ្រាយដើម ។

លោកបានប្រារព្ធធ្វើកិច្ចប្រជុំមួយរបស់សង្ឃ ដែលបានជ្រើសរើសសាវ័កល្បីៗចំនួន ៥០០ អង្គ ដែលជាព្រះអរហន្ត បានបដិសម្ភិទាញាណ ពោលគឺប្រាជ្ញាចាក់ធ្លុះនូវអ្វីទាំងពួងផ្ទាល់ និងមាន**វសី**លើពុទ្ធវចនៈ ដើម្បីសូត្រព្រះត្រៃបិដក ។ សង្គាយនានេះបានត្រូវប្រារព្ធធ្វើ តាមរចនាសម្ព័ន្ធ ដែលសាងសង់យ៉ាងពិសេសមួយ នៅខាងមុខគុហាសត្តបន្នី នៅក្រុងរាជគ្រឹះ ។

ព្រះបាទ**អជាតសត្រូវ** ជាព្រះរាជបុត្រ របស់ព្រះបាទពិម្ពិសារ បានធ្វើការរៀបចំភាពចាំបាច់ទាំងអស់ សម្រាប់ការធ្វើសង្គាយនានេះ ។ ព្រះរាជាទ្រង់បានឱ្យគេតាក់តែងមណ្ឌលឡើង នៅខាងមុខគុហាសត្តបន្នី ហើយបានថ្វាយនូវបច្ច័យទាំងបួន សម្រាប់ព្រះអរហន្តជាមហាថេរ និងអ្នកដទៃទៀតដែលបានចូលរួមក្នុងសង្គាយនា ។

បន្ទាប់ពីការរៀបចំបានសព្វគ្រប់អស់ហើយ, មហាសង្គាយនាបានចាប់ផ្តើមនៅខែទី ៤ បន្ទាប់ពីមហាបរិនិព្វាន របស់ព្រះសម្មាសម្ពុទ្ធ ។ សង្គាយនាលើកទី ១ ជាប្រវត្តិសាស្ត្រនេះ ប្រើពេលអស់ ៧ ខែ ដែលនៅក្នុងនោះសាវ័កដែលបានអភិញ្ញាចំនួន ៥០០ អង្គ បានប្រជុំគ្នាសូត្រនូវព្រះត្រៃបិដក ។

ព្រះ**មហាកស្សបត្ថេរ** ដែលជាព្រះអរហន្តចាស់វស្សាជាងគេបង្អស់ បានធ្វើជាអធិបតីលើសង្គាយនានេះ ។ ដំបូងលោកបានចោទសួរព្រះ**ឧបាលី** ជាវិន័យធរៈ អំពីវិន័យបិដក ដែលផ្ទុកនូវក្បួនច្បាប់វិន័យ ដែលព្រះសម្មាសម្ពុទ្ធទ្រង់បានបញ្ញត្តិ ថាតើនៅពេលណា កន្លែងណា ហើយហេតុអ្វីបានជាព្រះអង្គបញ្ញត្តិសិក្ខាបទនោះជាដើម ។ ហើយព្រះឧបាលី បានឆ្លើយបញ្ហាកម្មទាំងអស់ដោយពិស្តារ ។

ក្នុងទំនងដូចគ្នានេះដែរ, ព្រះ**អានន្ទ** ជាធម្មធរៈ និងជាមាតិកាធរៈ បានឆ្លើយនូវបញ្ហាកម្ម អំពីព្រះសូត្រ និងព្រះអភិធម្មបិដក ។ **មាតិកា** គឺជាឈ្មោះមួយទៀត សម្រាប់អភិធម្មបិដក ។ ដូចនេះពុទ្ធវចនៈទាំងស្រុង ពោលគឺព្រះត្រៃបិដកបានត្រូវសូត្រ និងធ្វើឱ្យមានសុពលភាព ដោយព្រះអរហន្តទាំង ៥០០អង្គនោះ ។ នេះគឺជារបៀប ដែលពុទ្ធវចនៈត្រូវបានការពារ និងរក្សាទុកដោយបរិសុទ្ធតាមទ្រង់ទ្រាយដើម ដូចដែលមាន នាពេលបច្ចុប្បន្ន ។

**សំនួរទី២៦**: **ចូរសរសេររៀបរាប់ ពីព្រឹត្តិការណ៍សង្គាយនាលើកទី ២ ។**

**ចម្លើយ:** សង្គាយនាលើកទី ២ បានប្រារព្ធធ្វើឡើងនៅឯ**វេលុការាម** ក្នុងក្រុង**វេសាលី**, ១០០ ឆ្នាំ បន្ទាប់ពីមហាបរិនិព្វានរបស់ព្រះសម្មាសម្ពុទ្ធ ។ គោលបំណងសម្រាប់សង្គាយនាលើកទី២មានដូចតទៅះ

## **សំនួរ និង ចម្លើយ**

ដោយបានបួសជាសង្ឃ ពួក**វជ្ជីបុត្រ**ជាច្រើន ពុំបានគោរពតាមធម៌វិន័យ ដែលសម្តែងដោយព្រះសម្មាសម្ពុទ្ធឡើយ។ ផ្ទុយទៅវិញ, ពួកគេរស់នៅតាមរបៀបខ្លួនឯង រំលោភបំពាន ច្បាប់វិន័យ ដែលបញ្ញត្តិដោយព្រះពុទ្ធ ។ ហើយលើសពីនោះទៀត, ពួកគេបានបង្កើតក្បួនវិន័យ ដោយខ្លួនឯង ដើម្បីបំពេញបែបផែនជីវិតធូររលុងរបស់ពួកគេ ។

ព្រះ**យសត្ថេរ** ជាសាវ័កផ្ទាល់របស់ព្រះអានន្ទ បានដឹងពីការឃ្លាតចាកព្រះវិន័យរបស់ព្រះសង្ឃ ។ បន្ទាប់ពីបានប្រមើលឃើញ ពីការគំរាមកំហែងដល់ពុទ្ធសាសនា នាពេលអនាគត ដោយបដិសម្ភិទាញាណ, លោកបានធ្វើសច្ចាប្រណិធានយ៉ាងម៉ឺងមាត់ ដើម្បីធ្វើសង្គាយនាលើកទី ២ ដើម្បីរក្សានូវពុទ្ធវចនៈ ។

ពួកវជ្ជីភិក្ខុបានបង្កើតវិន័យ ១០ យ៉ាង ដោយខ្លួនឯង ដែលមិនត្រឹមតែប្រឆាំង នឹងវិន័យដែលបញ្ញត្តិ ដោយព្រះសម្មាសម្ពុទ្ធ ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបំផ្លាញនូវស្មារតីនៃវិន័យ, ហេតុនេះ នឹងជាការគំរាមកំហែងយ៉ាងខ្លាំងក្លា ចំពោះពុទ្ធសាសនា ។ វិន័យ ១០ យ៉ាងនោះគឺ៖

### **១) កប្បតិ សិង្គិលោន កប្បោ ។**

អនុញ្ញាតឱ្យយួរអំបិលក្នុងខ្លាក់ស្នែង ក្នុងអំឡុងពេលបិណ្ឌបាត្រ ដើម្បីដាក់ថែមធ្វើឱ្យមានរសជាតិដល់ចង្ហាន់ ។ ការប្រតិបត្តិនេះប្រឆាំងនឹងវិន័យបាចិត្តិយសិក្ខាបទទី ៣៨ ទាក់ទងទៅនឹងការ

មិនឱ្យលាក់ទុកអាហារ (**សន្និធិការកៈ**) ដែលបានបញ្ញត្តិ ដោយព្រះសម្មាសម្ពុទ្ធ ក្នុងក្រុង**សាវត្ថី** ។

២) **កប្បតិ ទ្វង្គុល កប្បោ** ។

អនុញ្ញាតឱ្យឆាន់ បន្ទាប់ពីព្រះអាទិត្យ ជ្រេទៅបានពីរធ្នាប់ ចាប់ពីពេលថ្ងៃរសៀល ដែលជាការឆាន់ខុសពេលវេលា (**វិកាលភោជនៈ**) ។ ការប្រតិបត្តិនេះរំលោភបំពាន នូវវិន័យបាចិត្តិយ សិក្ខាបទទី ៣៧ ទាក់ទងនឹងការបរិភោគ ឬការឆាន់អាហារខុសកាល ដែលបានបញ្ញត្តិ ដោយព្រះសម្មាសម្ពុទ្ធ ក្នុងក្រុង**រាជគ្រឹះ** ។

៣) **កប្បតិ គាមន្តរ កប្បោ** ។

អនុញ្ញាតឱ្យឆាន់ពីរដងក្នុងភូមិមួយ ។ ការប្រតិបត្តិនេះប្រឆាំងនឹងវិន័យបាចិត្តិយ ត្រង់សិក្ខាបទទី ៣៦ ទាក់ទងទៅនឹងការឆាន់ពីរដង នៅក្នុងភូមិដដែល ព្រះសម្មាសម្ពុទ្ធទ្រង់បានបញ្ញត្តិក្នុងក្រុង**សាវត្ថី** ។

៤) **កប្បតិ អាវាស កប្បោ** ។

អនុញ្ញាតឱ្យធ្វើឧបោសថ ដាច់ដោយឡែកពីគ្នា ក្នុងខណៈកំពុងស្នាក់ នៅក្នុងអាវាសតែមួយ ។ ការប្រតិបត្តិនេះប្រឆាំងនឹងវិន័យបាចិត្តិយ **ហៅថាធ្វើទុក្កដ** ដែលទាក់ទងជាមួយឧបោសថដែលជាការប្រជុំ សូត្របាតិមោក្ខជាក្រុមនៅក្នុងអាវាសតែមួយ ដែលបានបញ្ញត្តិ ដោយព្រះសម្មាសម្ពុទ្ធ ក្នុងក្រុង**រាជគ្រឹះ** ។

៥) **កប្បតិ អនុមតិ កប្បោ** ។

## សំនួរ និង ចម្លើយ

អនុញ្ញាតឱ្យធ្វើសង្ឃកម្ម ដោយគ្មានវត្តមាននៃសមាជិកពាក់ព័ន្ធទាំងអស់ហើយ រំពឹងគិតថាភិក្ខុទាំងឡាយ ដែលជាអ្នកអវត្តមាន នឹងយល់ព្រមដោយស្ម័យប្រវត្តិ ។ ការប្រតិបត្តិនេះប្រឆាំងនឹងវិន័យបាចិត្តិយ **ហៅថាធ្វើទុក្កដ** ដែលទាក់ទងនឹងការធ្វើសង្ឃកម្មជាក្រុម ដូចដែលបានបញ្ញត្តិ ដោយព្រះសម្មាសម្ពុទ្ធ ក្នុងក្រុង**ចម្បេយ្យកៈ** ។

**៦) កប្បតិ អាចិន្ន កប្បោ ។**

អនុញ្ញាតឱ្យប្រតិបត្តិ តាមព្រះថេរៈទាំងងងឹតងងល់ ដោយនិយាយថា ព្រោះគ្រូ ឬឧបជ្ឈាយ៍របស់អាត្មាអញបានធ្វើវាដូច្នេះ អាត្មាក៏នឹងធ្វើតាមដូច្នោះដែរ, ដោយគ្មានការយល់ដឹង ពីគោលបំណងនៃការធ្វើដូចនោះឡើយ ។ ការប្រតិបត្តិនេះប្រឆាំងនឹងវិន័យបាចិត្តិយ ដែលទាក់ទងនឹងការប្រតិបត្តិ ដោយមិនបានសួរនាំ។

**៧) កប្បតិ អមថិត កប្បោ ។**

អនុញ្ញាតឱ្យឆាន់ទឹកដោះគោមានជាតិទធិ (ប៊ឺរ) ក្នុងកាលខុស ។ ការប្រតិបត្តិនេះប្រឆាំង នឹងវិន័យបាចិត្តិយ ដែលបានបញ្ញត្តិដោយព្រះសម្មាសម្ពុទ្ធ ក្នុងក្រុង**សាវត្ថី** ។

**៨) កប្បតិ ជលោគិ កប្បោ ។**

អនុញ្ញាតឱ្យឆាន់គ្រឿងស្រវឹងគឺសុរា ។ ការប្រតិបត្តិនេះប្រឆាំងនឹងវិន័យបាចិត្តិយ ដែលទាក់ទងនឹងការផឹកគ្រឿងស្រវឹង

និងគ្រឿងត្រាំទាំងឡាយ ដែលបញ្ញត្តិដោយព្រះសម្មាសម្ពុទ្ធ នៅក្រុង**កោសម្ពី** ។

**៩) កប្បតិ អទសកំ និសីទន កប្បោ ។**

អនុញ្ញាតឱ្យប្រើកម្រាលគ្រែថ្លៃៗ និងទាន់សម័យ ។ ការប្រតិបត្តិនេះប្រឆាំងនឹងវិន័យបាចិត្តិយ ដែលទាក់ទងនឹងការប្រើកម្រាលគ្រែនានា ។ល។ ដែលបានបញ្ញត្តិដោយព្រះសម្មាសម្ពុទ្ធ ក្នុងក្រុង**សាវត្ថី** ។

**១០) កប្បតិ ជាតរូប រជត កប្បោ ។**

អនុញ្ញាតឱ្យប្រើមាស ប្រាក់ ។ល។ ការប្រតិបត្តិនេះ ប្រឆាំងនឹងវិន័យបាចិត្តិយ ទាក់ទងនឹងការប្រើប្រាស់បច្ច័យ មាស និងប្រាក់ ។ល។ ដូចដែលបានបញ្ញត្តិ ដោយព្រះសម្មាសម្ពុទ្ធ នៅក្រុង**រាជគ្រឹះ**។

គ្រានោះឯង ព្រះ**យសត្ថេរ**បន្ទាប់ពីបានធ្វើសាធារណៈមតិប្រឆាំងនឹងការប្រតិបត្តិឱនថយទាំងនេះ របស់ពួកវជ្ជីភិក្ខុមក ក៏បានពិភាក្សាបញ្ហានេះ ជាមួយព្រះ**រេវតត្ថេរ** និងព្រះ**សព្វកាមិត្ថេរ**ដ៏មានអាយុ ។

ព្រះអរហន្តចាស់វស្សាទាំងបីអង្គនេះ រួមជាមួយនឹងព្រះអរហន្តចំនួន ៧០០ អង្គដទៃទៀត ដែលសុទ្ធតែជាអ្នក បរិបូណ៌ដោយបដិសម្ភិទាញាណ ក៏បាននិមន្តទៅកាន់វាលុការាមមហាវ័នដើម្បីធ្វើសង្គាយនាលើកទី ២ ។

## សំនួរ និង ចម្លើយ

ដោយហេតុបានដឹងពីការនិមន្តមក របស់ពួកព្រះអរហន្តទាំងនេះ, ពួកវជ្ជីភិក្ខុបានធ្វើសេចក្តីរាយការណ៍ក្លែងក្លាយថ្វាយស្តេច ដោយនិយាយថា ពួកភិក្ខុក្លែងក្លាយបានមកកំចាត់ពួកខ្លួន ពីមហាវ័ននោះ ។

ស្តេច ដែលជាសាវ័ករបស់ភិក្ខុក្លែងក្លាយទាំងនោះ បានបញ្ជូនមន្ត្រីរបស់ព្រះអង្គមកភ្លាម ដើម្បីទៅកំចាត់ព្រះអរហន្ត ដែលបានមកពីវាលុការាម ។ ប៉ុន្តែនៅពេលដែលមន្ត្រីនោះ ទៅដល់ទីនោះ, គាត់ពុំបានឃើញ សូម្បីតែព្រះសង្ឃមួយអង្គ នៅក្នុងមហាវ័ននោះឡើយ ។ ដូច្នេះគាត់ត្រឡប់មកវិញ ហើយរាយការណ៍រឿងនេះថ្វាយស្តេច ។

អព្ភូតហេតុ នៃការធ្វើមិនឱ្យឃើញ នូវរឿងទាំងនោះ គឺបណ្តាលឡើង ដោយ**សក្កទេវិន្ទ្រាធិរាជ** ដើម្បីឱ្យពួកអរហន្ត ដែលទើបតែនិមន្តមក ហើយអស់កម្លាំង ដោយដំណើរផ្លូវឆ្ងាយ ដើម្បីកុំឱ្យមានក្តីរំខាន ដល់ពួកលោក ។

នៅពេលយប់នោះ ស្តេច**កាលាសោក** បានសុបិន្តថា ព្រះអង្គកំពុងត្រូវបានធ្វើទារុណកម្ម ក្នុងលោហកុម្ភីនរក ដែលកំពុងដុតព្រះអង្គ ក្នុងខ្ទះដែកធំមួយ ពោរពេញដោយខ្លាញ់កំពុងពុះ ។

ក្នុងសុបិន្ត, ព្រះមហាក្សត្រ ទ្រង់បានមានអារម្មណ៍ថា ហាក់ដូចជាព្រះអង្គកំពុងត្រូវបានធ្វើទារុណកម្ម យ៉ាងជាក់ស្តែងនៅក្នុងនរកនោះ ។

នៅក្នុងខណៈពេលនោះឯង បងស្រីរបស់ព្រះអង្គ ឈ្មោះ **នន្ទាថេរី** ដែលជាព្រះអរហន្តមួយអង្គបានលេចមុខចំពោះព្រះអង្គ ហើយនិយាយដូច្នេះថា "អ្វីដែលអ្នកឯងកំពុងជួបប្រទះឥឡូវនេះ គឺដោយសារអ្នកឯងឧបត្ថម្ភព្រះសង្ឃក្លែងក្លាយ ហើយមិនអើពើចំពោះព្រះសង្ឃពិតប្រាកដ ដែលបានមកមហាវ័ន ដើម្បីធ្វើសង្គាយនាលើកទី ២ នេះ ប្រសិនបើអ្នកឯងបន្តឧបត្ថម្ភលោកទាំង នោះទៀត, អ្នកនឹងរងទុក្ខដូច្នេះ នៅក្នុងនរក នៅជាតិក្រោយទៀត។ ដោយបានឮដូច្នេះ ស្តេចអង្គនេះបានផ្លាស់ប្តូរឥរិយាបថទាំងស្រុង, ហើយបានក្លាយជាឧបាសកដ៏ល្អមួយរូប ។ គឺស្តេចអង្គនេះហើយ ដែលបានរៀបចំភាពចាំបាច់ទាំងអស់ សម្រាប់ធ្វើសង្គាយនាលើកទី ២ នេះ ។ ពេលនេះព្រះអរហន្តទាំង ៧០០ អង្គនេះ បានធ្វើមហាសង្គាយនាលើកទី ២ អស់រយៈពេល ៨ ខែ នៅវាលុការាម ក្នុងមហាវ័ន ជិតក្រុងវេសាលី ក្រោមអធិបតីភាព នៃព្រះមហាសព្វកាមិត្ថេរ ។ ដូចនេះព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ ដ៏បរិសុទ្ធបែបដើម បានត្រូវរក្សាទុកសារជាថ្មីទៀត ។

**សំនួរទី២៧**: **ចូរសរសេររៀបរាប់សង្គាយនាលើកទី៣ ។**

**ចម្លើយ:** មហាសង្គាយនាលើកទី ៣ បានប្រារព្ធធ្វើឡើងប្រហែល ២៥០ ឆ្នាំ បន្ទាប់ពីមហាបរិនិព្វាន របស់ព្រះសម្មាសម្ពុទ្ធ នៅ**អសោការាម បាដលីបុត្ត រាជធានីមគធៈ** ។ សង្គាយនានេះធ្វើអស់រយៈពេល ៩ ខែ ក្រោមការឧបត្ថម្ភរបស់ព្រះបាទអសោក ។

# សំនួរ និង ចម្លើយ

ព្រះអរហន្ត បានបដិសម្ភិទាញាណចំនួន ១០០០ អង្គ ក្រោមអធិ-បតីភាពព្រះអរហន្ត នាម មហា**មោគ្គលីបុត្តិស្សត្ថេរ** បានប្រជុំសូត្រព្រះត្រៃបិដកទាំងស្រុង ។

បុព្វហេតុនៃសង្គាយនាលើកទី ៣ គឺបណ្ដាលមកពីមានព្រះសង្ឃក្លែងក្លាយ កាន់តែច្រើនឡើង ដោយបានបួសជាសង្ឃខ្លួនឯង ហើយស្នាក់នៅជាមួយព្រះសង្ឃ ដែលល្អបរិសុទ្ធ ។ ព្រះសង្ឃទាំងនោះមិនរៀន និងប្រតិបត្តិតាមធម៌វិន័យនោះទេ ។ ផ្ទុយទៅវិញ គេផ្សព្វផ្សាយធម៌ក្លែងក្លាយ ផ្អែកលើមិច្ឆាទិដ្ឋិរបស់ពួកគេផ្ទាល់ ។ ដូចនេះធ្វើឱ្យមានការគំរាមកំហែងដល់ព្រះពុទ្ធសាសនា ។

ពួកសង្ឃទាំងនោះកើតមានឡើង ដោយសារតែរឿងលាភសក្ការៈ និងយសបានជះទៅលើភិក្ខុសង្ឃ និងភិក្ខុនីសង្ឃទាំងឡាយទាំងស្ដេច និងសាធារណជន ។ លាភ និងយសទាំងនេះ បានទាក់ទាញ ដល់ជនអាក្រក់ ដែលចង់ដឹកនាំជីវិត ប្រកបដោយភាពប្រណីត ។ នៅពេលដែលចំនួនភិក្ខុក្លែងក្លាយកើនច្រើនឡើងបានធ្វើឱ្យមានការគំរាមកំហែង ដល់ពុទ្ធសាសនាយ៉ាងខ្លាំងក្លា ។ លាភនិងយសទាំងឡាយបានកើតឡើង បន្ទាប់ពីព្រះបាទអសោក បានងាកចិត្តគំនិត មកកាន់ព្រះពុទ្ធសាសនា ។ មុនពេលប្ដូរមកកាន់ព្រះពុទ្ធសាសនា គេហៅឈ្មោះព្រះអង្គថា **ចណ្ឌាសោក** (អសោកឃោរឃៅ) ព្រោះព្រះអង្គជាស្ដេចឃោឃៅខ្លាំងណាស់ ។ ព្រះអង្គមានបងប្អូនប្រុសចំនួន ១០០ នាក់ ដែលប្រយុទ្ធគ្នាឯង

ដណ្ដើមរាជសម្បត្តិ ។ ដោយឃើញសារៈប្រយោជន៍ នៃចំណុចខ្សោយនេះ, អសោកក៏បានឡើងស្នងរាជ ធ្វើជាស្ដេច បន្ទាប់ពីការចូលទីវង្គត់ នៃបិតារបស់ព្រះអង្គនាម **ពិន្ទុសារ** គិតជាឆ្នាំ គឺ ២២០ ឆ្នាំ បន្ទាប់ពីមហាបរិនិព្វានរបស់ព្រះសម្មាសម្ពុទ្ធ ។

**អសោក** គឺមានប្រាជ្ញា និងក្លាហានយ៉ាងក្រៃលែង ។ នៅពេលដែលព្រះអង្គបានលូតលាស់, ព្រះអង្គក្លាយជាមានអំណាច ហើយអាចប្រយុទ្ធឈ្នះរាជាណាចក្រ ដ៏មានអំណាចបំផុតរបស់ **កលិង្គៈ** (ក្លឹង) ហើយបានក្លាយជាស្ដេចចុល្លចក្រពត្តិ ។

ទោះបីជាព្រះអង្គបានឡើងសោយរាជ្យជាស្ដេច ដែលមានអំណាច និងល្បីឈ្មោះបំផុតក៏ដោយ, ប៉ុន្តែព្រះអង្គក៏ជាស្ដេច ដែលមិនសប្បាយចិត្តបំផុត នៅក្នុងលោកផងដែរ ដោយសារតែទង្វើអាក្រក់របស់ព្រះអង្គ ។

ថ្ងៃមួយ នៅពេលដែលព្រះអង្គកំពុងយាងចង្ក្រមទៅមក ជិតទីប៉ាឆាមួយ ដោយព្រះទ័យខ្វល់ខ្វាយ, ព្រះថេរៈមួយអង្គ ឈ្មោះ **និគ្រោធ** ដែលកំពុងធ្វើភាវនាមួយអង្គឯង នៅក្នុងទីប៉ាឆានោះដែរ បានឃើញព្រះអង្គស្ថិតក្នុងល័ក្ខខ័ណ្ឌ នៃសេចក្ដីទុក្ខបែបនេះ ក៏មានអារម្មណ៍ អាណិតអាសូរយ៉ាងខ្លាំង ហើយហៅព្រះនាមព្រះអង្គផ្ទាល់ ៣ ដងថា "**ទេវានម្បិយៈ** សូមមកនេះ" ។

ក្រៅពីមាតារបស់ព្រះអង្គផ្ទាល់ គ្មាននរណាហ៊ានហៅឈ្មោះព្រះអង្គផ្ទាល់ ដូច្នេះឡើយ ។ ការហៅនេះបានធ្វើឱ្យព្រះបាទ

# សំនួរ និង ចម្លើយ

អសោកទ្រង់ព្រះពិរោធខ្លាំងណាស់ ហើយព្រះអង្គតាមសំឡេងពីកន្លែងដែលហៅនោះ ។ ប៉ុន្តែនៅពេលដែលព្រះអង្គខិតទៅជិតបានឃើញ ព្រះថេរៈនិគ្រោធ ព្រះអង្គក៏បាននៅស្ងៀម ។ ព្រះថេរៈបានមានថេរដីកា ទៅកាន់ព្រះអង្គដោយទន់ភ្លន់ ហើយបានសម្តែងប្រាប់ព្រះអង្គ អំពីផលនៃសេចក្តីទុក្ខ ដែលកើតចេញពីអំពើអាក្រក់។ បានឮដូចនេះ ព្រះអង្គបានធ្វើការផ្លាស់ប្តូរទាំងស្រុង ។ ពីឈ្មោះចណ្ឌាសោក (អសោកឃោឃៅ) ព្រះអង្គក្លាយទៅជាធម្មាសោក (អសោកប្រកបដោយធម៌) ។

នៅពេលនោះស្ថានភាពសមាគមសង្ឃ កំពុងមានសភាពអាក្រក់ ហើយព្រះសង្ឃដែលល្អបរិសុទ្ធ បានបដិសេធមិនព្រមធ្វើឧបោសថ ជាមួយព្រះសង្ឃអាក្រក់ ។ ដោយបានឮដូច្នេះ ព្រះបាទអសោកបានបញ្ជូនមន្ត្រី របស់ព្រះអង្គម្នាក់ ដែលមានចរិតសាហាវឃោរឃៅ ដោយសុំឱ្យភិក្ខុទាំងឡាយធ្វើឧបោសថជាមួយគ្នា ដើម្បីការរក្សា នូវព្រះពុទ្ធសាសនា ។

មន្ត្រីរូបនោះ ដោយពុំបានស៊ើបអង្កេតជាមុន បានបញ្ជាឱ្យព្រះសង្ឃធ្វើឧបោសថ ។ នៅពេលដែលព្រះសង្ឃបរិសុទ្ធបានបដិសេធជាមួយគាត់ៗ ខឹងហើយបានសម្លាប់ព្រះសង្ឃជាច្រើន ។ នៅពេលស្តេចបានឮឧបទ្ទវហេតុនេះ, ព្រះអង្គមានការភ្ញាក់ផ្អើលហើយបានហៅមន្ត្រីនោះមកសួរថា ហេតុអ្វីបានជាអ្នកសម្លាប់ព្រះសង្ឃ ? មន្ត្រីនោះឆ្លើយថា គាត់បានធ្វើដូច្នេះ ពីព្រោះគាត់គិតថា

ស្ដេចចង់ឱ្យគាត់ធ្វើតាមរបៀបនេះ ។ ស្ដេចមានព្រះទ័យសោក ស្ដាយយ៉ាងខ្លាំង ហើយបានយាងទៅកាន់សំណាក់ ព្រះមហា មោគ្គលីបុត្តិស្សត្ថេរ ដែលកំពុងគង់នៅក្បែរឆ្នេរ នៃស្ទឹងម្ខាង ហើយ បានសួរលោកថា តើនរណាជាអ្នកទទួលខុសត្រូវចំពោះទង្វើអា-ក្រក់បែបនេះ ។ ព្រះមោគ្គលីបុត្តិស្សត្ថេរបានអះអាងចំពោះ ព្រះ អង្គថា ដោយសារព្រះអង្គមិនមានបំណងបែបនេះ ហើយក៏មិនបាន បញ្ជាឱ្យធ្វើ, ដូចនេះព្រះអង្គមិនមែនជាអ្នកទទួលខុសត្រូវក្នុងរឿង សម្លាប់នេះទេ ។ គឺមន្ត្រីនោះដែលបានធ្វើវាដោយខ្លួនឯង ដូច្នេះ គាត់គឺជាអ្នកទទួលខុសត្រូវក្នុងរឿងនេះ, ហើយគាត់នឹងសោយទុក្ខ ចំពោះទង្វើបែបនេះ ។

ពេលនោះ ស្ដេចអសោកបានចង់រៀនព្រះធម៌បន្ថែមទៀត ហើយបានស្នាក់នៅជាមួយគ្រូរបស់ព្រះអង្គរយៈពេល ១ សប្ដាហ៍ ពេញ ។ ក្នុងពេលនោះ ព្រះអង្គបានរៀន ពីរបៀបវិនិច្ឆ័យ និងបែង ចែករវាងព្រះសង្ឃល្អ និងព្រះសង្ឃអាក្រក់ ។ បន្ទាប់ពីការបវារណា ចេញវស្សា, ព្រះអង្គបាននិមន្តគ្រូរបស់ព្រះអង្គមកកាន់ព្រះរាជវាំង ហើយបានសួរលោកថា គួរធ្វើយ៉ាងម៉េចជាមួយសង្ឃក្លែងក្លាយ ។ គ្រូរបស់ព្រះអង្គបានប្រាប់ព្រះអង្គថា ដំបូងសង្គមសង្ឃត្រូវធ្វើឱ្យ បរិសុទ្ធ ដោយបណ្ដេញសង្ឃក្លែងក្លាយ ចេញពីសង្ឃជាមុនសិន, ហើយបន្ទាប់មក ត្រូវធ្វើសង្គាយនាលើកទី ៣ ដើម្បីភាពបរិសុទ្ធ នៃ ព្រះធម៌ឡើងវិញ ។ បន្ទាប់មក ស្ដេចអសោកបានរៀបចំពិធីផ្សឹក

ដោយការសាងមណ្ឌលពីរកន្លែង, មណ្ឌលមួយសម្រាប់ព្រះសង្ឃល្អ និងមណ្ឌលមួយទៀតសម្រាប់ព្រះសង្ឃអាក្រក់ ។

បន្ទាប់មក ព្រះអង្គបាននិមន្ត ព្រះសង្ឃនៅក្នុងប្រទេសទាំងអស់ ។ ខណៈដែលព្រះមហាមោគ្គលីបុត្តិស្សត្ថេរ បានរៀបចំសំនួរ ១000 សំនួរ ដើម្បីសាកល្បងចំណេះដឹងផ្នែកព្រះធម៌របស់ពួកគេ ដែលឱ្យឈ្មោះថា កថាវត្ថុ ។ បច្ចុប្បន្ន គម្ពីរនេះជាផ្នែកមួយ នៃគម្ពីរអភិធម្មបិដក ។

នៅពេលដែលការរៀបចំភាពចាំបាច់ទាំងអស់ បានធ្វើចប់សព្វគ្រប់, ពិធីផ្សឹកបានចាប់ផ្ដើម ដោយសួរសំនួរនីមួយៗ ចំពោះព្រះសង្ឃ ។ ភិក្ខុដែលមិនអាចឆ្លើយសំនួរចំនួនជាង ៦0.000 អង្គត្រូវបានបណ្ដេញចេញពីសង្ឃ ។ ហើយចំពោះព្រះសង្ឃដែលបានឆ្លើយសំនួរបានត្រឹមត្រូវ បានត្រូវប្រព្រឹត្ត ដោយសេចក្ដីគោរពយ៉ាងក្រៃលែង ។

ឥឡូវ ពេលដែលព្រះអង្គមានការយល់ដឹងពីព្រះធម៌បានកាន់តែប្រសើរច្រើនឡើង, ព្រះអង្គថែមទាំងក្លាយជាស្ដេច មានចិត្តសប្បុរស និងប្រកបដោយគន្លងធម៌ ។ ព្រះអង្គបានឈប់សម្លាប់សត្វ ក្នុងរាជាណាចក្ររបស់ព្រះអង្គ ។ ព្រះអង្គបានសាងមិត្តភាពយ៉ាងស្និទ្ធស្នាល ជាមួយរាជាណាចក្រជិតខាង ។ ព្រះអង្គមិនមែនល្អសម្រាប់ខ្លួនឯងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានធ្វើល្អចំពោះអ្នកដទៃ ដោយបម្រើសេវាកម្មដល់មនុស្សជាតិ ។ ព្រះអង្គបានតែង

តាំងទាហាន របស់ព្រះអង្គទាំងអស់ និងព្រះសង្ឃ ដែលត្រូវបណ្ដេញចេញ ចំនួន ៦០.០០០ នាក់ ឱ្យទៅជាសេវាកម្មមនុស្សជាតិវិញ ។ ជាលើកដំបូងនៃប្រវត្តិសាស្ត្រ របស់មនុស្សជាតិហើយដែលព្រះអង្គបានសាងមន្ទីរពេទ្យសម្រាប់ព្រះសង្ឃ ដូនជី និងសាធារណជន ថែមទាំងសម្រាប់សត្វពាហានៈ និងបក្សីទាំងឡាយផង ។ ព្រះអង្គបានសាងវត្តអារាម និងទីសក្ការៈបូជា បានលើកឡើងនូវសសរស្តម្ភនៃព្រះធម៌ ដែលឥឡូវនេះក្លាយជានិមិត្តរូបរបស់សាធារណរដ្ឋឥណ្ឌា ឱ្យគេចារពុទ្ធវចនៈលើផ្ទាំងថ្ម ហើយដាក់បង្គោ-លនោះឡើងគ្រប់ទីកន្លែង ដែលគេឃើញមានសូម្បីតែសព្វថ្ងៃនេះ, ហើយបានដាំដើមឈើតាមដងផ្លូវ និងសាងធម្មសាលាជាដើម ។

បន្ទាប់ពីបានធ្វើសង្ឃឱ្យបរិសុទ្ធមក, ព្រះសង្ឃដែលល្អបរិសុទ្ធបានសម្រេចចិត្តធ្វើការលើកកំពស់នៃព្រះធម៌ ដោយការធ្វើសង្គាយនាលើកទី ៣ ។ ស្ដេចអសោកបានឱ្យរៀបចំនូវភាពចាំបាច់សព្វបែបយ៉ាងភ្លាម ហើយនិមន្តព្រះសង្ឃទាំងអស់ឱ្យមកចូលធ្វើសង្គាយនា ។ ក្នុងចំណោមនោះ ព្រះអរហត្តបដិសម្ភិទាចំនួន ១០០០ អង្គបានសូត្រព្រះត្រៃបិដកទាំងស្រុង ខណៈដែលព្រះមោគ្គលីបុត្តិស្សត្ថេរ ធ្វើជាអធិបតីលើសង្គាយនា ដែលប្រព្រឹត្តទៅអស់រយៈពេល ៩ ខែ ។ ដល់ម្លឹងហើយ! ស្ដេចអសោកមិនទាន់ពេញចិត្តជាមួយអ្វីដែលជាអំពើល្អ ដែលព្រះអង្គទ្រង់បានធ្វើ រហូតដល់ពេលនេះឡើយ ។ ដូច្នេះព្រះអង្គបានសួរគ្រូរបស់ព្រះអង្គ តើ

## សំនួរ និង ចម្លើយ

សេវាកម្មអ្វី ដែលអស្ចារ្យបំផុត ដែលខ្ញុំព្រះករុណាអាចធ្វើបាន ចំពោះព្រះពុទ្ធសាសនា ? ព្រះមោគ្គលីបុត្តិស្សត្ថេរ បានពិត្រទូល ព្រះអង្គថា សូមឱ្យ**មហិន្ទ** ព្រះរាជបុត្រា និង**សង្ឃមិត្តា** ព្រះរាជបុត្រី ព្រះអង្គបួសជាសង្ឃ, នេះជាសេវាកម្មដ៏អស្ចារ្យបំផុត ដែលព្រះអង្គ អាចធ្វើបាន ។ ស្តេចអសោកបានប្រទានបុត្រទាំងពីរ របស់ព្រះអង្គ ដល់សង្ឃ ដោយគ្មានស្ទាក់ស្ទើរ ដោយព្រះរាជបុត្រាបុត្រីទាំងពីរ បានកំពុងរង់ចាំជាស្រេច ដើម្បីធ្វើដូច្នេះដែរ ។ ស្តេចអសោកមិន មែនត្រឹមតែបានផ្សព្វផ្សាយព្រះធម៌ក្នុងប្រទេស របស់ព្រះអង្គផ្ទាល់ តែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានបញ្ជូនធម្មទូត ចំនួន ៩ អង្គ ទៅ កាន់ប្រទេសដទៃជាច្រើនទៀត។ ព្រះរាជបុត្រានិងបុត្រី របស់ព្រះ អង្គបានត្រូវបញ្ជូនទៅកាន់ប្រទេសស្រីលង្កា ។ អសោក គឺជារាជា-ធិរាជដំបូងបង្អស់ ដែលបាននាំមកនូវបដិវត្តន៍ ដ៏ពិតអស្ចារ្យមួយ ក្នុងប្រទេសឥណ្ឌា ហើយលទ្ធផលនោះ ត្រូវបានដឹងឮរហូតដល់ សព្វថ្ងៃ និងព្រះនាមរបស់ព្រះអង្គបានរីកស្គុសស្គាយ ក្នុងបេះដូង របស់ប្រជារាស្ត្រ ។ ឯធម្មទូតទាំង ៩ អង្គ ដែលព្រះអង្គបានបញ្ជូន ទៅផ្សព្វផ្សាយពុទ្ធសាសនា ទាំង ៩ កន្លែងនោះ គឺ៖

**១) គន្ធារៈ និង កាស្មិរៈ** (កាស្មៀរ និងប្រទេសភាគខាង ជើង និងខាងលិចរបស់កាស្មៀរ រាប់ទាំងអាហ្វហ្គានីស្ថានបច្ចុប្បន្ន និងប្រទេសនៅអាស៊ីភាគកណ្តាលមួយចំនួនទៀត) ក្រោមអធិបតី ភាពព្រះអរហន្ត នាម **មជ្ឈន្តិកៈ** ជាមួយនឹងព្រះថេរៈ មួយក្រុម។

**២) យោនកៈ** (ម៉ាសេដូនី ក្រិច), (រាប់បញ្ចូលទាំងរដ្ឋគ្រិកូ-បាទ្រីយៀងរបស់អឺរ៉ុប អ៊ីស្រាអែលបច្ចុប្បន្ន សេរីយ៉ា អ៊ីរ៉ាក់ និងអេហ្ស៊ីបត៍), ក្រោមអធិបតីភាពព្រះអរហន្ត នាម **មហារក្ខិតៈ** និងព្រះថេរៈទាំងឡាយមួយក្រុម ។

**៣) ចិនហិមវន្ត** (ប្រទេសចិន និងប្រទេសទាំងឡាយនៅតាមជួរភ្នំហិមាល័យ គឺឡាដាកហ៍, ហិមាឆាល នេប៉ាល់ ទីបេ ប៊ូតង់ និងសិក្កឹម), ក្រោមអធិបតីភាពព្រះអរហន្ត នាម **មជ្ឈិមត្ថេរ** និងព្រះថេរៈទាំងឡាយមួយក្រុម ។

**៤)សុវណ្ណភូមិ** (ភូមា និងប្រទេសនៅអាស៊ីអាគ្នេយ៍ គឺថៃ កម្ពុជា ឡាវ ម៉ាឡេ ឥណ្ឌូនេស៊ី និងវៀតណាម), ក្រោមអធិបតីភាពព្រះអរហន្ត នាម **សោណៈ** និង**ឧត្តរៈ** ព្រមទាំងព្រះថេរៈមួយក្រុម ។

**៥) ស្រីលង្កា** ក្រោមអធិបតីភាពព្រះអរហន្ត នាម **មហិន្ទ** និងភិក្ខុមួយក្រុមមានគ្នា ៥ រូប ។

**៦) មហិឞ្សកមណ្ឌល** (កន៌តកៈ និងរដ្ឋដេកង់រាប់ទាំងអន្ទ្រៈ), ក្រោមការដឹកនាំរបស់ព្រះអរហន្ត នាម **មហាទេវ** និងក្រុមភិក្ខុមួយក្រុម ។

**៧) មហារដ្ឋៈ** (មហារដ្ឋបច្ចុប្បន្ន និងមធ្យមប្រទេស), ក្រោមការដឹកនាំរបស់ព្រះអរហន្ត នាម**មហាធម្មរក្ខិតៈ** និងភិក្ខុមួយក្រុម។

**៨) វនវាសី** (ឥណ្ឌាភាគខាងត្បូង រាប់ទាំងកន៌តកៈ គោ និងកេរលៈ), ក្រោមការដឹកនាំរបស់ព្រះអរហន្ត នាម **រក្ខិតៈ** និង

ក្រុមភិក្ខុមួយក្រុម។

**៩) អបរន្តកៈ** (ឥណ្ឌាភាគខាងលិច រាប់ទាំងគុជរដ្ឋបច្ចុប្បន្ន រាជស្ថាន និងប៉ាគីស្ថាន), ក្រោមការដឹកនាំរបស់ព្រះអរហន្ត នាម **យោនកៈ** (ជាជនជាតិក្រិច) នាម **ធម្មរក្ខិតៈ** និងក្រុមភិក្ខុមួយក្រុម ។

ក្រៅពីការផ្សព្វផ្សាយធម៌, មហាធម្មសាសនទូតទាំងនេះ បានចូលរួមជួយ តាមមធ្យោបាយដ៏អត់ធ្មត់បំផុត ផ្នែកអារ្យធម៌ក្នុង តំបន់ដ៏ធំទូលាយ និងក្នុងចំណោមជាតិសាសន៍ទាំងឡាយ សម័យ ដើម ដែលជារឿយៗមានអរិភាព ។ នេះគឺពិតជាសេវាកម្មគួរយក ជាគំរូមួយ ដល់មនុស្សជាតិ និងអ្វីមួយដែលល្អឯក នៅក្នុងប្រវត្តិ-សាស្ត្រ នៃពិភពលោក ។

**សំនួរទី២៨: ចូរសរសេររៀបរាប់ ពីព្រឹត្តិការណ៍សង្គាយនា លើកទី ៤ ។**

**ចម្លើយ:** មហាសង្គាយនា លើកទី ៤ បានប្រារព្ធធ្វើឡើង ក្នុងអំឡុង ៤៥០ ឆ្នាំ បន្ទាប់ពីមហាបរិនិព្វាន របស់ព្រះសម្មាសម្ពុទ្ធ។ សង្គាយនានេះបានត្រូវធ្វើឡើង នៅប្រទេសស្រីលង្កា នៅឯ**អលុ-លេនគុហា** ។ ធ្វើជាអធិបតីដោយព្រះ**រក្ខិតត្ថេរ** ដែលមានព្រះ អរហន្តចំនួន ៥០០ អង្គ ប្រជុំសូត្រព្រះត្រៃបិដកជាច្រើនសា, បន្ទាប់ មក រួចស្រេចហើយក៏បានចារ ជាលាយល័ក្ខណ៍អក្សរលើស្លឹករឹត ។

នៅពេលនោះ, ប្រទេសស្រីលង្កាស្ថិតក្នុងស្ថានភាព យ៉ាង អាក្រក់ ដោយសារតែស្តេចពាល មានអរិភាពចំពោះព្រះសង្ឃ ។

ដូច្នេះ នៅពេលដែលព្រះសង្ឃចំនួន ១០០០ អង្គបានចាកចេញពីទីក្រុង**អនុរាធបុរៈ**, វាបានក្លាយទៅជាទីក្រុងមួយទទេសូន្យ ខាងផ្លូវប្រតិបត្តិពុទ្ធសាសនា ។ ចំណែកឯភិក្ខុដទៃទៀតចំនួន ៧០០ អង្គបាននិមន្តទៅប្រទេសឥណ្ឌា ភាគខាងត្បូង ហើយទោះជាយ៉ាងម៉េចក៏ដោយ ឱ្យតែបានរស់នៅ ។ ព្រះសង្ឃចំនួន ៥០ អង្គបានត្រឡប់មកនៅឆ្នេរសមុទ្រ រស់នៅអាស្រ័យដោយស្លឹកឈើ និងផ្លែឈើជាដើម ។ ដោយសារកង្វះជាតិអាហារ, ពួកភិក្ខុទាំងនោះបានថមថយកម្លាំង ខ្សោយរាងកាយ រហូតដល់ពួកលោកពុំអាចឈរ ឬដើរបាន គឺព្រោះតែដើម្បីការរក្សានូវពុទ្ធវចនៈ ពោលគឺដោយសារព្រះធម៌របស់ព្រះពុទ្ធទ្រង់បានសម្តែងនេះហើយ ទើបពួកគេទ្រាំនៅទីនោះ ។ ពួកភិក្ខុទាំងនោះសឹងលើដីសូត្រព្រះត្រៃបិដក, ចំណែកពួកភិក្ខុដទៃទៀត នៅមានកម្លាំងបាននិមន្តទៅព្រៃ នៅក្បែរនោះដើម្បីបេះផ្លែឈើ និងស្លឹកឈើធ្វើចង្ហាន់ ។ល។ ហើយឆាន់ទាំងអស់អង្គ ។ ពួកភិក្ខុនោះរស់នៅតាមរបៀបនេះ អស់រយៈពេល ១២ ឆ្នាំ ។

ស្តេច**ចណ្ឌាតិស្សៈ** នៃប្រទេសស្រីលង្កា មិនមែនត្រឹមតែបង្ខំព្រះសង្ឃ ឱ្យចាកចេញពីទីក្រុងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបំផ្លាញវត្តអារាមរបស់ព្រះពុទ្ធសាសនា មជ្ឈមណ្ឌលសិក្សា និងទីសក្ការៈបូជាទាំងអស់ ។ បន្ទាប់មក ដោយពេលវេលាចេះតែកន្លងទៅ, ស្ថានភាពបានផ្លាស់ប្តូរភ្លាម ។ ដោយស្តេចពាលនេះសោយទីវង្គត់

ទៅ, ហើយព្រះរាជបុត្ររបស់ព្រះអង្គឈ្មោះ **វដ្តគាមិនីអភ័យ** បានឡើងជាស្តេច ។ ស្តេចអង្គនេះផ្ទុយស្រឡះពីបិតារបស់ព្រះអង្គ គឺព្រះអង្គជាស្តេចដែលមានសប្បុរសធម៌ ។ ព្រះអង្គបានមានព្រះទ័យសោកស្តាយ ចំពោះអ្វីដែលបិតា របស់ព្រះអង្គបានធ្វើ ហើយបានសុំខមាទោស ចំពោះព្រះសង្ឃ សម្រាប់រាល់ភាពលំបាកលំបិនទាំងអស់ ដែលលោកបានជួបប្រទះ ។ ព្រះអង្គបាននិមន្តព្រះសង្ឃចូលមកទីក្រុងវិញ ដើម្បីបន្តធ្វើបេសកកម្មផ្នែកព្រះធម៌ ដូចមុន ដើម្បីជាសុខុមាលភាព ដល់ជនទូទៅ ។ ព្រះអង្គក៏បានស្ថាបនាវត្តអារាម និងទីសក្ការៈបូជា ដែលបំផ្លាញ ដោយបិតារបស់ព្រះអង្គឡើងវិញ ។

ទោះបីជាព្រះសង្ឃជាច្រើន បានត្រឡប់មកទីក្រុងវិញក៏ដោយ ក៏ព្រះអរហន្តចំនួន ៥០០ អង្គ ពុំបានត្រឡប់មកវិញដែរ ដោយសារព្រះអរហត្តទាំងនោះបានប្តេជ្ញាចិត្ត ធ្វើសង្គាយនាលើក ទី ៤ ដើម្បីរក្សាព្រះធម៌តាមទម្រង់ដើម ។ បន្ទាប់ពីបានឮការធ្វើសង្គាយនាលើកទី ៤ ដូចនេះ, ស្តេចបានឱ្យគេធ្វើការរៀបចំទាំងអស់ ។ ពេលនោះសង្គាយនាបានប្រារព្ធធ្វើឡើង ក្រោមអធិបតីភាព ព្រះ**រក្ខិតត្ថេរ** ដែលមានព្រះអរហត្តចំនួន ៥០០ អង្គសូត្រព្រះត្រៃបិដកទាំងស្រុង ជាច្រើនសា ដើម្បីបញ្ជាក់នូវភាពពិត តាមច្បាប់ដើម របស់ធម៌វិន័យ ។

ពីមុនមក ពុទ្ធវចនៈទាំងឡាយបានត្រូវផ្តល់ និងរក្សាទុកដោយការចាំមាត់ ពីគ្រូទៅសិស្ស ។ នេះជាលើកដំបូងហើយ ដែល

ព្រះត្រៃបិដកទាំងស្រុងត្រូវបានចារជាលាយល័ក្ខណ៍អក្សរ លើសស្ត្រាស្លឹករឹត ។ ដោយជាក់ស្តែង សិល្បៈនៃការសរសេរបានត្រូវអភិវឌ្ឍជាស្រេច ។ បន្ទាប់ពីការប្រែត្រៃបិដក ទៅជាការសរសេរជាអក្សរ, គម្ពីរនេះបានត្រូវគេថ្វាយដល់ស្តេច ហើយព្រះអង្គក៏បាន ឱ្យធ្វើការ ចម្លងជាច្រើនច្បាប់ ហើយចែកចាយ គម្ពីរព្រះត្រៃបិដកនោះទៅដល់វត្តអារាម ពុទ្ធសាសនាទាំងអស់ ។ សាស្ត្រាស្លឹករឹតបុរាណត្រូវបានរក្សាទុក និងធ្វើគោរពបូជាដោយប្រជាជន សូម្បីតែសព្វថ្ងៃនេះ ។

**សំនួរទី២៩**: **ចូររៀបរាប់សង្គាយនាលើកទី ៥ ឱ្យបានពិស្តារ។**

**ចម្លើយ:** ២៤១៤ ឆ្នាំ បន្ទាប់ពីមហាបរិនិព្វាន របស់ព្រះសម្មាសម្ពុទ្ធ, ក្នុងឆ្នាំ ១៨៧១ ក្រោមការឧបត្ថម្ភ របស់ស្តេច**មីនដុន** នៃប្រទេសមីយ៉ាន់ម៉ា (ប្រទេសភូមា), គម្ពីរ**ព្រះត្រៃបិដក** និង**អដ្ឋកថា** បានត្រូវសូត្រ អស់រយៈពេល ៥ ខែ ហើយត្រូវបានចារឹកលើផ្ទាំងថ្មម៉ាប (ថ្មើមថ្ម) ចំនួន ៧២៩ ផ្ទាំង (គឺអដ្ឋកថា ៥០០ ផ្ទាំង ព្រះត្រៃបិដក ២២៩ ផ្ទាំង)។ ព្រះថេរៈ ២៤០០ អង្គ ដែលជាភ្ញៀវកិត្តិយស នៃប្រទេសផ្សេងៗ បាននិមន្តមកចូលរួម ក្នុងសង្គាយនានេះ នៅទីក្រុង**មណ្ឌលេ** (ទីក្រុងចាស់របស់ប្រទេសភូមា)។ ផ្ទាំងថ្មទាំងនេះ, ផ្ទាំងនីមួយៗត្រូវបានដម្កល់ទុកក្នុងចេតីយ៍នីមួយៗ ហើយត្រូវបានរក្សាទុកយ៉ាងហ្មត់ចត់ក្រោមល័ក្ខខ័ណ្ឌដ៏ល្អឥតខ្ចោះ រហូត

ដល់សព្វថ្ងៃនេះ។ សង្គាយនានេះឈ្មោះថា សង្គាយនាលើកទី ៥ ។ ក្នុងសង្គាយនាលើកទី ៤ នៅប្រទេសស្រីលង្កាព្រះត្រៃបិដក គ្រាន់តែបានចារលើស្លឹករឹតប៉ុណ្ណោះ។ ស្តេច **មីនដុន** ទ្រង់មានព្រះតម្រិះឃើញថា ការចារព្រះត្រៃបិដកលើស្លឹករឹតដូច្នេះ ងាយនឹងធ្វើឱ្យអន្តរាយ ខូចខាតដោយកណ្តៀរ កណ្តុរ និងសត្វល្អិតដទៃទៀតបំផ្លាញ ។ល។ ទើបស្តេចអង្គនេះ ទ្រង់សម្រេចព្រះទ័យថា ត្រូវតែចារព្រះត្រៃបិដកលើផ្ទាំងថ្ម ទើបអាចរក្សាទុកបានយូរ អស់រយៈ-កាល៥០០០ព្រះវស្សានៃអាយុកាលសាសនាព្រះពុទ្ធគោតមហើយក៏ទ្រង់ឱ្យគេធ្វើការនេះឡើង ចប់សព្វគ្រប់ហើយ ធ្វើសង្គាយនាទី ៥ នេះ ឡើងតែម្តង។

**សំនួរទី៣០**: ចូរសរសេររៀបរាប់សង្គាយនាលើកទី ៦ តើបានត្រូវប្រារព្ធធ្វើនៅកន្លែងណា ?

**ចម្លើយ:** ក្នុងការរំលឹក នៃពិធីបុណ្យខួបពុទ្ធសាសនា ២៥០០ ឆ្នាំ, ក្នុងខែឧសភា ឆ្នាំ១៩៥៤, មហាសង្ឃអន្តរជាតិមួយដែលមានព្រះថេរៈល្បីៗចំនួន២៥០០ អង្គមកពីប្រទេសផ្សេងៗគឺៈ មីយ៉ាន់ម៉ា ថៃ ស្រីលង្កា កម្ពុជា ឡាវ ឥណ្ឌា បង់ក្លាដេស និងមកពីប្រទេសផ្សេងៗទៀត ដូចជា ចិន ជប៉ុន នេប៉ាល់ ។ល។, បាននិមន្តមកចូលរួម ក្នុងសង្គាយនាលើកទី ៦ ដែលប្រារព្ធធ្វើឡើងនៅទីក្រុង**យ៉ាំងហ្គូន** (ឈ្មោះហៅពីមុន រ៉ង្គូន), ក្រោមការឧបត្ថម្ភរបស់រដ្ឋាភិបាលមីយ៉ាន់ម៉ា (ឈ្មោះហៅពីមុន **ភូមា**) ។ នាយករដ្ឋ-

មន្ត្រី របស់ប្រទេសមីយ៉ាន់ម៉ា គឺលោក**អ៊ុនុ** បានដើរតួយ៉ាងសំខាន់ក្នុងការរៀបចំធ្វើសង្គាយនានេះ ដែលបាននាំមកការពិនិត្យអត្ថបទតាមសំណៅដៃ ដ៏រុងរឿងមួយ ផ្នែកគម្ពីរ**ព្រះត្រៃបិដក អដ្ឋកថា** និង **ដីកា** ជាអក្សរមីយ៉ាន់ម៉ា (ភូមា) ។ ការព្យាយាមធ្វើកិច្ចការដ៏ប្រសើនេះ បានឈានដល់ទីបញ្ចប់ នៅថ្ងៃពេញបូរមី ខែវិសាខ (ឧសភា) ឆ្នាំ១៩៥៦ ជាការកត់ចំណាំខួបទី ២៥០០ ឆ្នាំ នៃមហាបរិនិព្វានរបស់ព្រះសម្មាសម្ពុទ្ធ។

តាមព្រឹត្តិការណ៍ខាងលើ គឺច្បាស់ណាស់ថា ក្នុងសង្គាយនាលើកទី ១ គម្ពីរបាលីបានចាត់ជាក្រុម រៀបតាមលំដាប់ហើយតម្កល់រក្សាទុកនូវភាពបរិសុទ្ធ តាមច្បាប់ដើមនៃធម៌ របស់ព្រះសម្មាសម្ពុទ្ធ, ក្នុងសង្គាយនាលើកទី ២ រាល់វិវាទទាំងអស់ ទាក់ទងនឹងវិន័យដូចមានផ្ទុកក្នុងគម្ពីរវិន័យបិដក ត្រូវបានគាស់រំលើងបំបាត់ទាំងអស់ភ្លាម, ក្នុងសង្គាយនាលើកទី៣ រាល់ការបកស្រាយ តាមបែបទស្សនវិជ្ជា និងការរំពឹងគិតតាមន័យប្រៀបធៀបបានត្រូវក្តិចចោលនូវពន្លករបស់វា ហើយភាពបរិសុទ្ធរបស់ព្រះធម៌ ត្រូវបានប្រកាសឡើងវិញ, សង្គាយនាលើកទី ៤ បានកត់ត្រាគម្ពីរបិដក និងគម្ពីរដីកាដទៃទៀតជាលាយលក្ខណ៍អក្សរ ។ ដូច្នេះការរក្សាទុកនូវ ព្រះធម៌ តាមច្បាប់ដើម ដោយព្រះពុទ្ធសាសនាថេរវាទ បានធ្វើឡើងយ៉ាងលំបាក ។ លើសពីនេះទៅទៀត, សង្គាយនាបានចាក់គ្រឹះយ៉ាងរឹងមាំ សម្រាប់

## សំនួរ និង ចម្លើយ

ការរីកលូតលាស់ ផ្នែកគម្ពីរអនុបិដកជាភាសាបាលី ដែលក្រោយមកបានរីករាលដាល កាន់តែច្រើនឡើងៗ ។

*ទោះជននោះស្វាធ្យាយគម្ពីរបានតិចតួចក្តី, ប៉ុន្តែប្រតិបត្តិតាមធម៌នោះ, ដើម្បីលះបង់រាគៈ ទោសៈ និងមោហៈ, ដោយបញ្ញាឃើញពិត និងចិត្តដែលរួចរដោះចាកទុក្ខ, មិនប្រកាន់មាំចំពោះលោកនេះ និងលោកដទៃ ជននោះឈ្មោះថាបានផលពីការប្រតិបត្តិព្រហ្មចរិយធម៌ដោយពិត ។*

ធម្មបទលេខ.២០

**ពហុំ វេ សរណំ យន្តិ, បព្វតានិ វនានិច អារាម រុក្ខចេតិយានិចមនុស្សា ភយតជ្ជិតា ។**

*ដោយសេចក្តីភ័យខ្លាច, ជនទាំងឡាយតែងរកទីពឹង ចំពោះទីកន្លែងជាច្រើន ដូចជា ភ្នំ ព្រៃឈើ អារាម ដើមឈើ និងចេតិយទាំងឡាយ។*

ធម្មបទលេខ.១៨៨

**ប្រវត្តិភាសា និងអក្សរសាស្ត្របាលី**

**នេតំ ខោ សរណំ,ខេមំ នេតំ សរណមុត្តមំ នេតំ សរណមាគម្ម សព្វទុក្ខា បមុច្ចតិ ។**

*មែនពិត ទីពឹងបែបនេះ មិនមែនជាទីពឹងដ៏ក្សេម,*

*ទីពឹងបែបនេះ មិនមែនជាទីពឹង ដ៏ឧត្តម។*

*មិនមែនស្វែងរក ទីពឹងបែបនេះ ឈ្មោះថា*

*បុគ្គលនោះ បានរួចចាកទុក្ខទាំងពួងឡើយ។*

ធម្មបទលេខ.១៨៩

មានតែទីពឹងក្នុងព្រះ**ពុទ្ធ**ព្រះ**ធម៌**ព្រះ**សង្ឃ**ទើបជាទីពឹងដ៏ប្រសើរ, ជាទីពឹងអាចធ្វើឱ្យយើងរួចចាកទុក្ខទាំងពួង ក្នុងសង្សារវដ្ត។

៚

**ពុទ្ធសាសនំ ចិរំ តិដ្ឋតុ**

សូមឱ្យពុទ្ធសាសនាឋិតថេរជារៀងរហូត!

**ចប់**

❄ **សៀវភៅដែលខ្ញុំបានប្រែរៀបរៀង និងបានបោះពុម្ពរួចហើយ៖**

*១. ជីវិតធម៌, បោះពុម្ពនៅឆ្នាំ ២០០៣*

*២. ហេតុអ្វីយើងគប្បីប្រតិបត្តិតាមព្រះពុទ្ធសាសនា, បោះពុម្ពឆ្នាំ ២០១១*

➢ **សៀវភៅដែលខ្ញុំបានប្រែរៀបរៀង និងនៅមិនទាន់បានបោះពុម្ព៖**

*១. គុកជីវិត*

*២. កាមសូត្រ*

*៣. ព្រះពុទ្ធនៅឯណា?*

*៤. ទស្សនៈពុទ្ធសាសនាស្តីអំពីសួគ៌ និងនរក*

➢ **សៀវភៅដែលនិពន្ធដោយស្នាដៃខ្ញុំផ្ទាល់ហើយនៅមិនទាន់បោះពុម្ពជាសាធារណៈ៖**

*១. Analytical study of Anatta in Theory and practice*

*២. How to attain supreme happiness*

*៣. Buddhist view on caste system*

*៤. មន្តអាគមស័ក្តិសិទ្ធិគឺអ្វី?*

**ការពិនិត្យអក្ខរាវិរុទ្ធ** 

**គណៈកម្មការពិនិត្យអក្ខរាវិរុទ្ធ**

១. ភិក្ខុ **ស្រ៊ាង ទ៉ាន់ដា** សមណនិស្សិតពុទ្ធិកសាកលវិទ្យា-
ល័យព្រះសីហនុរាជ

២. កញ្ញា **គុជ ស្រីអូន** បរិញ្ញាបត្រធនាគារនិងហិរញ្ញវត្ថុ
សាកលវិទ្យាល័យបៀលប្រាយ

៣. លោក **ព្រំ ស៊ីណា** បរិញ្ញាបត្រទស្សនវិជ្ជាពុទ្ធសាសនា
សាកលវិទ្យាល័យពុទ្ធសាសនទូតថេរវាទអន្តរជាតិ

**រចនាក្របគម្រប**

ភិក្ខុ **ពៅ ធុវត្ថា** សមណនិស្សិតពុទ្ធិកសាកលវិទ្យាល័យ
ព្រះសីហនុរាជ

- **អ្នកមានឧបការគុណក្នុងការឧបត្ថម្ភខ្ញុំនូវបច្ច័យ៤**
  - ១. លោក **សេក សៀន** និងភរិយា **សម សាមន**
  - ២. បណ្ឌិត **ផែល ថោង**
  - ៣. អ្នកស្រី **ជូ សេរី**

# ប្រវត្តិរូបសង្ខេបរបស់អ្នកប្រែរៀបរៀងសៀវភៅ



**នាមៈ សឿង ឧត្តី**

**ភេទៈ** ប្រុស

**ថ្ងៃ ខែ ឆ្នាំកំណើតៈ** ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ១៩៧៨

**ទីកន្លែងកំណើតៈ** ភូមិពោធិ៍ ឃុំញរ ស្រុកកំពង់ពោធិ៍ ខេត្តស្វាយរៀង។

**ថ្ងៃខែឆ្នាំបំបួសៈ** ថ្ងៃទី ១៥ ខែ មករា ឆ្នាំ១៩៩៥ ក្នុងវត្តជម្ពូព្រឹក្សា ឃុំសង្ឃ័រស្រុកស្វាយទាបខេត្តស្វាយរៀង ព្រះឧបជ្ឈាយ៍នាម **ជេត ឱន** (**សីលសំវរោ**) គង់នៅវត្តវត្តជម្ពូព្រឹក្សា ឃុំសង្ឃ័រ ស្រុកស្វាយទាប ខេត្តស្វាយរៀង។

<u>ស្ថានភាពគ្រួសារៈ</u>

**ឪពុកឈ្មោះ នង ទន់** អាយុ ៦៨ ឆ្នាំ មុខរបរ កសិករ។

**ម្តាយឈ្មោះ អ៊ុន សន** អាយុ ៦៦ ឆ្នាំ មុខរបរ កសិករ។

**មានបងប្អូនចំនួនៈ** បងប្អូនបង្កើត ៣ នាក់ ប្រុស ២ ស្រី ១ ។
ខ្ញុំបាទជាកូនទី ២នៃគ្រួសារ។

**កំរិតវប្បធម៌:**

- ២០១១ សញ្ញាបត្រ អនុបណ្ឌិតទស្សនវិជ្ជាពុទ្ធសាសនា នៃសាកលវិទ្យាល័យពុទ្ធសាសនទូតថេរវាទអន្តរជាតិ ទីក្រុងយ៉ាំងហ្គូន សហភាពមីយ៉ាន់ម៉ា ។
- ២០០៧ សញ្ញាបត្រ បរិញ្ញាបត្រទស្សនវិជ្ជាពុទ្ធសាសនា នៃសាកលវិទ្យាល័យពុទ្ធសាសនទូតថេរវាទអន្តរជាតិ ទីក្រុងយ៉ាំងហ្គូន សហភាពមីយ៉ាន់ម៉ា ។
- ២០០៥ សញ្ញាបត្រឌីប្លូម នៃសាកលវិទ្យាល័យពុទ្ធសាសនទូតថេរវាទអន្តរជាតិ ទីក្រុងយ៉ាំងហ្គូន សហភាព មីយ៉ាន់ម៉ា ។

**បទពិសោធន៍ការងារ:**

- ២០០៤-២០១១, បំរើការងារ ជាទីប្រឹក្សាសម្រាប់សមាគម សមណនិស្សិតខ្មែរ ប្រចាំនៅទីក្រុងយ៉ាំងហ្គូន សហភាពមីយ៉ាន់ម៉ា ទទួលបន្ទុកខាងសរសេរ បកប្រែ និងត្រួតពិនិត្យអត្ថបទជាច្រើន ស្តីអំពីព្រះពុទ្ធសាសនា និងសង្គម។

# នាមអ្នកឧបត្ថម្ភបោះពុម្ពសៀវភៅនេះ

| | | | | |
|---|---|---|---|---|
| ១ | អ្នកស្រី | យី សាវី | និងកូនចៅ | $ ៣០ |
| ២ | ឧបាសិកា | តាន់ ណៃស៊ីន | និងកូនចៅ | $ ៤០ |
| ៣ | ឧបាសិកា | ស៊ុន ថាយ | និងកូនចៅ | $ ១០០ |
| ៤ | ឧបាសិកា | ម៉ែន សុទ្ធ | និងកូនចៅ | $ ២០ |
| ៥ | ឧបាសិកា | អៀច ថាវី | និងកូនចៅ | $ ១០ |
| ៦ | ឧបាសិកា | ស៊ឹម ណារ៉ប | និងកូនចៅ | $ ១០០ |
| ៧ | ឧបាសិកា | សេង សឿង | និងកូនចៅ | $ ១០ |
| ៨ | ឧបាសិកា | នាង ង៉ា | និងកូនចៅ | $ ៥ |
| ៩ | ឧបាសិកា | ជ គៀង | និងកូន | $ ៥ |
| ១០ | ឧបាសិកា | សំ ចន្ទី | និងកូនចៅ | $ ២០ |
| ១១ | ឧបាសិកា | សុង សឿម | និងកូនចៅ | $ ៥០ |
| ១២ | ឧបាសិកា | ធុល យ៉ត + ឧ.ស ឡេន ភ័ណ | និងកូន | $ ៣០ |
| ១៣ | ឧបាសិកា | ថម នៀង + ឧ.ស អ៊ូ អួន | និងកូនចៅ | $ ២០ |
| ១៤ | លោក | សោម សាម៉ន អ្នកស្រី សាន មុំ | និងកូន | $ ២០ |
| ១៥ | លោក | សេក សៀន អ្នកស្រី សម សាមន | និងកូន | $ ៥០ |
| ១៦ | សេក ចន្ទឆាយា + សីហា ទុំ | | និងកូន | $ ៥០ |
| ១៧ | សេក ចន្ទធារី | | និងកូន | $ ១០ |

| | | | | |
|---|---|---|---|---|
| ១៨ | សេក | ចន្ទសុភី + ម៉ែកូ | និងកូន | $ ១០ |
| ១៩ | សេក | ចន្ទសុផានី | | $ ១០ |
| ២០ | សេក | ចន្ទសុបុណ្ណារត្ន | | $ ១០ |
| ២១ | សេក | ចន្ទតារា | | $ ១០ |
| ២២ | សេក | ចន្ទសុបុណ្ណា + កូន | | $ ១០ |
| ២៣ | អ្នកស្រី | ហេ លេន | | $ ១០ |
| ២៤ | អ្នកស្រី | ថៃប អ៊ី | | $ ២០ |
| ២៥ | លោក | សំ បូលី + ឃុន ចាន់ថន | និងកូន | $ ១០ |
| ២៦ | ឧបាសក | ម៉ៅ សុខ ឧបាសិកា ម៉ា សារួត | និងកូន | $ ១០ |
| ២៧ | ឧបាសិកា | សេន ជឹម | និងកូនចៅ | $ ២០ |
| ២៨ | លោក | ឡេន ឈួន | និងកូន | $ ២០ |
| ២៩ | លោក | សំ ហ៊ាន សំយ៉ាន | និងកូន | $ ៥០ |
| ៣០ | កញ្ញា | ធន់ ធារី និស្សិតពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ | | $ ៥ |

# អង្គរបស់អ្នកសិក្សាមាន ៤ យ៉ាង

## សុ. ចិ. បុ. លិ

១. សុ : ឱ្យស្តាប់គេ

២. ចិ : រិះរេគិតចំណាំ

៣. បុ : ឱ្យសាកសួរសាំ

៤. លិ : ចំណាំកត់ត្រាទុក